ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសវនកម្មជាតិ

# របាយការណ៍សវនកម្ម
# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

លេខៈ ៦

ឆ្នាំ២០១៥

# របាយការណ៍សវនកម្ម
# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ការិយបរិច្ឆេទ ២០១១

# អារម្ភកថា

ការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ២០១១ នៅព្រះរាជាណាចក្រកម្ពុជា ត្រូវបានអនុវត្តនៅក្នុងស្ថានភាពដែលឥទ្ធិពលអវិជ្ជមាននៃការធ្លាក់ចុះសេដ្ឋកិច្ច និងវិបត្តិកលិយុគសកលលោកកំពុងថយចុះ ប៉ុន្តែវិបត្តិបំណុលនៅអឺរ៉ុបកំពុងរងឥទ្ធិពលធ្ងន់ធ្ងរ។ រីឯសភាពការណ៍ទំនាស់ព្រំដែននៅតំបន់ប្រាសាទព្រះវិហារត្រូវបានធូរស្រាលឡើងវិញខ្លះៗ ប៉ុន្តែកម្ពុជានៅបានប្រឈមនឹងគ្រោះទឹកជំនន់ដែលត្រូវបានបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរ។

ដើម្បីជំនះបាននូវឥទ្ធិពលអវិជ្ជមានពីខាងក្រៅ និងការប្រឈមទាំងនោះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនិងអនុវត្តគោលនយោបាយ និងវិធានការដ៏ត្រឹមត្រូវ ហ្មត់ចត់ ទន់ភ្លន់ និងទាន់ពេលវេលា ជាពិសេសឈរលើទស្សនៈនៃការដឹកនាំគ្រប់គ្រងសភាពការណ៍តាមបែបចល័តដែលបានធ្វើឱ្យរាជរដ្ឋាភិបាលសម្រេចបាននូវការអភិវឌ្ឍន៍លើវិស័យសំខាន់ៗ ដែលជាកត្តានាំឱ្យសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ជាងការគ្រោងទុកនៅក្នុងច្បាប់ថវិកាដើមឆ្នាំ២០១១។ ជាសក្ខីភាព សមិទ្ធផលទាំងនេះរបស់រាជរដ្ឋាភិបាលបានឆ្លុះបញ្ចាំង តាមរយៈចំណូលថវិកាថ្នាក់ជាតិ អនុវត្តបានប្រមាណ **១២,៣៨%** នៃផ.ស.ស[1] គឺបានកើនឡើង **៨,៥%** ធៀបទៅនឹងឆ្នាំ២០១០។ ចំណាយថវិកាថ្នាក់ជាតិសរុបអនុវត្តបានប្រមាណ **១៨,០០%** នៃ ផ.ស.ស គឺបានកើនឡើង **១១,៥%** ធៀបទៅនឹងឆ្នាំ២០១០។ ការអនុវត្តចំណូលនិងចំណាយនេះ បានធ្វើឱ្យមានអតិរេកចរន្តប្រមាណ **១,១៣%** នៃ ផ.ស.ស។

---

[1] សេចក្ដីថ្លែងហេតុនៃសេចក្ដីព្រាងច្បាប់ស្ដីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១១របស់រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី២៦ នៃតុលា ឆ្នាំ២០១២។

ថវិការាជធានី-ខេត្ត ចំណូលអនុវត្តបានខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុចំនួន **៧៧,៦%** ចំណាយអនុវត្តខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុចំនួន **៣២,៣%**។

ស្ថិតក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលបានរក្សាយ៉ាងខ្ជាប់ខ្ជួននូវវិន័យថវិកាដោយត្បិតត្បៀតចំណាយចរន្ត ដើម្បីរក្សាអតិរេកចរន្តសម្រាប់ការវិនិយោគទៅលើការកសាងហេដ្ឋារចនាសម្ព័ន្ធទាំងផ្នែករឹង និងផ្នែកទន់ ចំណាយលើការវិនិយោគ និងចំណាយលើកិច្ចការពារអធិបតេយ្យភាព ដែលជាមូលដ្ឋានសម្រាប់ពង្រឹងកិច្ចការពារបូរណភាពទឹកដី និងអធិបតេយ្យជាតិ សម្រាប់ពង្រឹង និងពង្រីកសកម្មភាពសេដ្ឋកិច្ច សង្គម បង្កើនចំណូល និងលើកកម្ពស់សេវាសាធារណៈជូនប្រជាពលរដ្ឋ។ សមិទ្ធផលទាំងនេះបានធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាមានកំណើន **៧,១%** នៅក្នុងឆ្នាំ២០១១ ធៀបនឹងការព្យាករណ៍ដើមឆ្នាំ២០១១ គ្រោងទុក **៦%** ប៉ុណ្ណោះ។ លទ្ធផលនៃកំណើនសេដ្ឋកិច្ចខាងលើនេះ បានធ្វើឱ្យចំណូលមធ្យមសម្រាប់ប្រជាជនម្នាក់ក្នុងមួយឆ្នាំសម្រាប់ឆ្នាំ២០១១ បានកើនឡើងដល់ **៩១១** ដុល្លារអាមេរិក គឺបានកើនឡើង **៩,៧%** ធៀបទៅនឹងឆ្នាំ២០១០ ដែលជាកត្តាធ្វើឱ្យសម្រេចបាននូវការកាត់បន្ថយអត្រានៃភាពក្រីក្របានជាង **១%** ក្នុងមួយឆ្នាំ គឺភាពក្រីក្របានធ្លាក់ចុះពី ៤៧,៨% នៅឆ្នាំ**២០០៧** មកនៅត្រឹម **១៩,៨%** **នាឆ្នាំ២០១១** ហើយចំណុចគោលដៅដែលនឹងត្រូវកាត់បន្ថយអត្រាភាពក្រីក្រឱ្យមកនៅត្រឹម **១៩,៥%** សម្រាប់ឆ្នាំ**២០១៥**[2]។

លទ្ធផលទាំងនេះ បានឆ្លុះបញ្ចាំងឱ្យឃើញពីភាពប្រសើរឡើងនៃកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជាពីមួយឆ្នាំទៅមួយឆ្នាំ។ សមិទ្ធផល

---

[2] របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០១៣ ស្តីពីការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ក្រសួងផែនការ ខែមេសា ឆ្នាំ២០១៤។

ទាំងនេះ គឺដោយសារការអនុវត្តថវិកាឆ្នាំ២០១១ បានត្រឹមត្រូវ និងមានប្រសិទ្ធភាពខ្ពស់។ ដូច្នេះ គឺជាការពិត និងជាការត្រឹមត្រូវណាស់ ដែលរាជរដ្ឋាភិបាលកម្ពុជា បានប្រសិទ្ធនាមថវិកាឆ្នាំ២០១១ នេះថា ជាថវិកាសម្រាប់បន្តពង្រឹង និងពង្រីកមូលដ្ឋានសេដ្ឋកិច្ច និងវឌ្ឍនភាពសង្គម តាមរយៈការបន្តរក្សាស្ថិរភាពនយោបាយ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ស្ថិរភាពហិរញ្ញវត្ថុសាធារណៈ ព្រមទាំងបន្តជំរុញការអភិវឌ្ឍន៍វិស័យគន្លឹះ ពិសេសវិស័យកសិកម្ម ឧស្សាហកម្ម ការពង្រឹង និងពង្រីកការអនុវត្តលទ្ធិប្រជាធិបតេយ្យ និងការអនុវត្តកម្មវិធីកំណែទម្រង់លើគ្រប់វិស័យឱ្យកាន់តែស៊ីជម្រៅ។

ជាមួយនឹងសមិទ្ធផលដ៏ធំធេង ដែលសម្រេចបានក្នុងឆ្នាំ២០១១នេះ បានសបញ្ជាក់យ៉ាងច្បាស់ថា ពិតជាបានមកដោយសារការដឹកនាំដ៏ត្រឹមត្រូវប្រកបដោយឆន្ទៈនយោបាយមោះមុត ឈ្លាសវៃ ភ្លឺស្វាង ប្រកបដោយគតិបណ្ឌិតខ្ពង់ខ្ពស់របស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញ និងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រត្រឹមត្រូវ ច្បាស់លាស់ សមស្រប ដឹកនាំ និងគ្រប់គ្រងតាមបែបចល័ត ព្រមទាំងមានរចនាសម្ព័ន្ធគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពខ្ពស់ និងភាពសក្តិសិទ្ធិ ធានារក្សាបាននូវឯករាជ្យភាព ឯកភាពជាតិ បូរណភាពទឹកដី និងអធិបតេយ្យជាតិ ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច មានកំណើនសេដ្ឋកិច្ចខ្ពស់ នាំឱ្យប្រទេសកម្ពុជាមានការអភិវឌ្ឍន៍យ៉ាងឆាប់រហ័ស ជីវភាពប្រជាពលរដ្ឋត្រូវបានលើកកម្ពស់ជាបន្តបន្ទាប់ ។

អាជ្ញាធរសវនកម្មជាតិ ជាស្ថាប័នសវនកម្មកំពូលមួយដែលត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជាក្នុងខែមីនា ឆ្នាំ២០០០ ក្រោមឆន្ទៈ និងការប្តេជ្ញាដ៏មោះមុតរបស់រាជរដ្ឋាភិបាល

រដ្ឋសភា ព្រឹទ្ធសភា ក្នុងគោលបំណងបំពេញមុខងារត្រួតពិនិត្យ វាយតម្លៃ និង ផ្តល់អនុសាសន៍កែលម្អរាល់ចំណុចខ្វះខាតរបស់ក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន អង្គភាពពាក់ព័ន្ធនានា និងធ្វើរបាយការណ៍ ស្តីពីលទ្ធផលសវនកម្មផ្ញើជូនរដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាល សំដៅរួមចំណែកពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កិច្ចប្រតិបត្តិការការងារ ឱ្យកាន់តែល្អប្រសើរ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

អាជ្ញាធរសវនកម្មជាតិផ្សព្វផ្សាយរបាយការណ៍សវនកម្មជាសាធារណៈ អនុលោមតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា។ របាយការណ៍នេះលើកឡើងនូវលទ្ធផលនៃការធ្វើសវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុលោមតាមបទប្បញ្ញត្តិ និងកិច្ចប្រតិបត្តិការការងារក្នុងការិយបរិច្ឆេទ២០១១ របស់ក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ និងអង្គភាពពាក់ព័ន្ធនានាមួយចំនួន។

ដោយការខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់ តស៊ូ អត់ធ្មត់ ព្យុះពារឆ្លងកាត់ការលំបាករបស់ថ្នាក់ដឹកនាំ និងមន្ត្រីសវនកម្មនៃអាជ្ញាធរសវនកម្មជាតិ ព្រមទាំងមានការជួយឧបត្ថម្ភគាំទ្រពីគ្រប់មជ្ឈដ្ឋានទាំងផ្នែកស្មារតី និងសម្ភារៈ បាននាំឱ្យអាជ្ញាធរសវនកម្មជាតិមានសក្តានុពលក្នុងការអនុវត្តការងារ និងសម្រេចបានជាបន្តបន្ទាប់នូវផែនការយុទ្ធសាស្ត្រ ២០០៧-២០១១របស់ខ្លួន។ ចំពោះមុខអាជ្ញាធរសវនកម្មជាតិនឹងបន្តខិតខំបន្ថែមទៀត ដោយធ្វើការពង្រីកវិសាលភាពសវនកម្ម ពង្រឹងសមត្ថភាពមន្ត្រី និងបង្កើនគុណភាពសវនកម្ម ដើម្បីឈានទៅសម្រេចភារកិច្ចតាមស្តង់ដារសវនកម្មជាតិ និងអន្តរជាតិ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការរបស់ប្រទេសជាតិ។

ក្នុងនាមអាជ្ញាធរសវនកម្មជាតិ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះរាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ដែលជានិច្ចកាលតែងតែគាំទ្រអាជ្ញាធរសវនកម្មជាតិទាំងស្មារតី និងសម្ភារ។ ម្យ៉ាងវិញទៀត ខ្ញុំក៏សូមអរគុណ និងកោតសរសើរចំពោះថ្នាក់ដឹកនាំ និងមន្ត្រីនៃអាជ្ញាធរសវនកម្មជាតិទាំងអស់ ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ធ្វើឱ្យសម្រេចបាននូវជោគជ័យគួរឱ្យកត់សម្គាល់។ ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំសូមថ្លែងអំណរគុណដល់អង្គភាពរងសវនកម្មនានា និងសាធារណជនទាំងឡាយដែលបានសហការ គាំទ្រ និងលើកទឹកចិត្ត ចំពោះរាល់ការងារបម្រើឱ្យវិស័យសវនកម្មសាធារណៈនាពេលកន្លងមក។ ជាមួយគ្នានេះដែរ ខ្ញុំសូមអរគុណផងដែរដល់អង្គការកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ (GIZ) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ធនាគារពិភពលោក (World Bank) អង្គការ DANIDA នៃប្រទេសដាណឺម៉ាក ព្រមទាំងដៃគូអភិវឌ្ឍន៍ និងស្ថាប័នសវនកម្មកំពូលនានាដែលបានផ្តល់ការគាំទ្រ និងឧបត្ថម្ភផ្សេងៗក្នុងកិច្ចដំណើរការអភិវឌ្ឍន៍ស្ថាប័ន។

អាជ្ញាធរសវនកម្មជាតិមានសង្ឃឹមយ៉ាងមុតមាំថា សកម្មភាពទាំងនេះនឹងនៅតែបន្តយ៉ាងសកម្ម ដែលបង្ហាញពីការចូលរួមចំណែកក្នុងការលើកស្ទួយ និងការអភិវឌ្ឍន៍ប្រទេសជាតិ ជាទីគោរព និងស្រឡាញ់នៃយើងទាំងអស់គ្នា។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០១៥

**អគ្គសវនករ**

**សោម គឹមសួគ៌**

# មាតិកា


សេចក្តីសង្ខេប ..................................................................១

១. សេចក្តីផ្តើម ..................................................................៥

១.១.លក្ខណៈទូទៅ ..................................................................៥

១.២.ការអនុវត្ត និងដែនកំណត់សវនកម្ម..................................................................៦

១.៣.គោលបំណងនៃការផ្សព្វផ្សាយ ..................................................................៧

២. ការគ្រប់គ្រងថវិកា ..................................................................៧

២.១.មូលដ្ឋានគតិយុត្តិនៃការអនុវត្តថវិកា..................................................................៧

២.២.កិច្ចប្រតិបត្តិការថវិកា ..................................................................៩

៣. លទ្ធផលសវនកម្ម ..................................................................១០

៣.១.ការគ្រប់គ្រងថវិកាថ្នាក់ជាតិ..................................................................១០

៣.១.១.ការប្រើប្រាស់ ឬការចេញវិក្កយបត្រឱ្យទៅអតិថិជន ..១០

៣.១.២.របាយការណ៍សវនកម្មរបស់សវនករឯករាជ្យ ...... ១២

៣.១.៣.យន្តការនៃការធ្វើសវនកម្មសហគ្រាស ............. ១៣

៣.១.៤.ការគ្រប់គ្រងចំណូលពីប្រាក់រំភាគទាន០,៥%នៃ
បុព្វលាភធុល ..................................................................១៥

៣.១.៥.ការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់
ទ្រព្យបញ្ចាំ ..................................................................១៦

៣.១.៦.ការផ្ញើរបាយការណ៍អាជីវកម្មអភិវឌ្ឍន៍អចលនវត្ថុទៅ
ក្រុមការងារអន្តរក្រសួង..................................................................១៨

៣.១.៧.ការធ្វើ និងការផ្ញើផែនការលទ្ធកម្មប្រចាំឆ្នាំទៅក្រសួង
សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ..................................................................២០

៣.១.៨.ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ.......................២២

**៣.២. ការគ្រប់គ្រងថវិកាថ្នាក់រាជធានី ខេត្ត** .................... ២៤
៣.២.១.ការប្រមូលពន្ធអចលនទ្រព្យ ................................ ២៤
៣.២.២.ការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ .......................... ២៦
៣.២.៣.ការបង្កើតក្រុមការងារតាមដានការសាងសង់ និង ជួសជុល .......................................................... ២៦
៣.២.៤.ការធ្វើសេចក្តីប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈ . ២៧
**៤. ការពិនិត្យទៅលើវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍ សវនកម្ម** .......................................................... ២៨
**៥. សេចក្តីសន្និដ្ឋាន** ............................................................ ៤១

# របាយការណ៍សវនកម្ម
# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់
# ការិយបរិច្ឆេទ២០១១

## សេចក្តីសង្ខេប

អាជ្ញាធរសវនកម្មជាតិ ជាស្ថាប័នសាធារណៈដែលឯករាជ្យអំពីកិច្ចប្រតិបត្តិការនៃការងារ និងមានភារកិច្ចចំពោះការអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល។ ស្ថាប័ននេះត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០។ អនុលោមតាមមាត្រា២ មាត្រា៣ មាត្រា២៩ និងមាត្រា៣៧ នៃច្បាប់នេះ អាជ្ញាធរសវនកម្មជាតិមានកាតព្វកិច្ចធ្វើសវនកម្ម និងផ្សព្វផ្សាយលទ្ធផលសវនកម្មដែលចាំបាច់។

ទោះបីកម្ពុជាបានជួបប្រទះនូវគ្រោះទឹកជំនន់ ស្ថានភាពសេដ្ឋកិច្ចនៅមានលក្ខណៈផុយស្រួយ និងមានហានិភ័យខ្ពស់យ៉ាងណាក្តី ដោយសារការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា នៅតែរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ច ៧,១% លើសពីការព្យាករណ៍ ដែលបានរំពឹងទុកចំនួន៦% ព្រមទាំងកាត់បន្ថយបាននូវភាពក្រីក្រជាង ១% ក្នុងមួយឆ្នាំ ដែលជាលទ្ធផលគួរឱ្យកត់សម្គាល់។

សម្រាប់ការិយបរិច្ឆេទ២០១១ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្មលើបណ្តាក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាល

មូលដ្ឋាន សហគ្រាសសាធារណៈ គម្រោងផ្សេងៗ និងសម្បទានវិនិយោគមួយចំនួន ដែលមានលទ្ធផលសង្ខេបខាងក្រោម៖

### ក. កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

ការអនុវត្តចំណូលតាមរយៈរតនាគារជាតិ សម្រេចបានចំនួន ៦.៦៦៨.៦៦៧,០លានរៀល ស្មើនឹង១២,៨% នៃ ផ.ស.ស គឺមានការកើនឡើង ៩,២% ធៀបទៅនឹងការអនុវត្តឆ្នាំ២០១០។ ទន្ទឹមនឹងលទ្ធផលដែលសម្រេចបាននេះ បើផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្មបានបង្ហាញឱ្យឃើញថា នៅមានប្រភេទចំណូលមួយចំនួនទៀត ដែលចាំបាច់ត្រូវធ្វើឱ្យប្រសើរឡើងថែមទៀត មានជាអាទិ៍៖ ការត្រួតពិនិត្យលើការប្រើប្រាស់វិក្កយបត្រ ការអនុវត្តកាតព្វកិច្ចពេញលេញ ក្នុងការដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់ការធ្វើសវនកម្មគណនេយ្យសហគ្រាស ការអនុវត្តយន្តការនៃការធ្វើសវនកម្មសហគ្រាស ការបង្វែរចូលថវិកានូវចំណូលពីប្រាក់ភាគលាភបុព្វលាភផុតរបស់ក្រុមហ៊ុនធានារ៉ាប់រង ការអនុវត្តតួនាទីត្រួតពិនិត្យលើការគ្រប់គ្រងប្រមូលពន្ធ ការអនុវត្តវិធានការតឹងទារបំណុលពន្ធឱ្យបានពេញលេញ ការអនុវត្តមុខងារសវនកម្មលើអ្នកជាប់ពន្ធ ការគ្រប់គ្រង និងតាមដានសកម្មភាពអាជីវកម្មសហគ្រាស ការប្រកាសពន្ធ និងអាកររបស់សហគ្រាស ការបញ្ចូលមូលដ្ឋានអាជីវកម្មរបបមៅការទៅរបបស្វ័យប្រកាសឱ្យបាន កិច្ចសហការជិតស្និទ្ធរវាងអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្នុងការគ្រប់គ្រង និងតាមដានសកម្មភាពអាជីវកម្មសហគ្រាស ការជម្រះផ្ទេរចំណូលពន្ធគយ និងពន្ធដារចូលថវិកា ការជម្រះផ្ទេរចូល

ថវិកានូវចំណូលពីការលក់ទំនិញរឹបអូស និងទំនិញបាត់ឃ្លាំង ការត្រួតពិនិត្យតាមដានលើការប្រើប្រាស់ទំនិញនាំចូលក្រោមរបបអនុគ្រោះពន្ធនានា ការប្រឹងប្រែងទារបំណុលដែលត្រូវសង។ល។

ការអនុវត្តចំណាយតាមរយៈរតនាគារជាតិ សម្រេចបានចំនួន ៧.២៩១.៦៩១,៨លានរៀល ស្មើនឹង ១៤,០% នៃ ផ.ស.ស គឺកើនឡើង ១១,៩% ធៀបទៅនឹងការអនុវត្តឆ្នាំ២០១០ ហើយស្មើនឹង ១០០,៦% នៃច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ២០១១ ដែលបានកំណត់ចំនួន ៧.២៤៩.៦៥២,០លានរៀល ដែលនាំឱ្យមានឱនភាពថវិកាស្មើនឹង ១,២% នៃ ផ.ស.ស។ នៅក្នុងការអនុវត្តចំណាយថវិកានេះមានចំណុចគួរឱ្យកត់សម្គាល់មួយចំនួនដូចជា៖ ការធ្វើផែនការលទ្ធកម្ម និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈមិនទាន់បានសមស្រប ការដកចំណូលយកទៅចំណាយដោយមិនបានកត់ត្រាចូលថវិកា ការបើកផ្តល់ និងការទូទាត់មួយចំនួនមិនទាន់ពេលវេលា ការទូទាត់ និងការកត់ត្រាចំណាយមិនអនុលោមតាមគោលការណ៍ហិរញ្ញវត្ថុ ភាពយឺតយ៉ាវក្នុងការទូទាត់ថវិកាបុរេប្រទាន។

កិច្ចប្រតិបត្តិការថវិកាអនុវត្តក្រៅរតនាគារជាតិ ត្រូវបានគ្រោងទុកដោយមានតុល្យភាពចំណូលសរុបស្មើនឹងចំណាយសរុប។ កិច្ចប្រតិបត្តិការនេះ សម្រេចបានចំនួន ៣.៤០២.៦៩១,៨ លានរៀល ស្មើនឹង ១៣០,៩% នៃផែនការដែលមានចំនួន ២.៦០០.០០០,០ លានរៀល។

## ខ. កិច្ចប្រតិបត្តិការថវិការាជធានី ខេត្ត

ការអនុវត្តចំណូលសម្រេចបានចំនួន ៦៣៤.៩៥៤ លានរៀល ស្មើនឹង ១៧៧,៦% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១១ ដែលបានកំណត់

ចំនួន ៣៥៧.៥៨៣ លានរៀល។ រីឯការអនុវត្តចំណាយសម្រេចបានចំនួន ៤៧២.៩៨៤ លានរៀល ស្មើនឹង ១៣២,៣% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១១ ដែលបានកំណត់ចំនួន ៣៥៧.៥៨៣ លានរៀល គឺមានអតិរេករវាងចំណូល និងចំណាយចំនួន ១៦១.៩៧០ លានរៀល។ ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញមានបញ្ហាគួរឱ្យកត់សម្គាល់ដូចជា៖ ការប្រមូលពន្ធអចលនទ្រព្យនៅមានកម្រិត ការអនុវត្តប្រមូលពន្ធតាមរបបមៅការមិនទាន់បានសមស្រប ការមិនទាន់បានបញ្ចូលមូលដ្ឋានអាជីវកម្មមួយចំនួនទៅក្នុងបញ្ជីអនុម័តពន្ធឱ្យបានទាន់ពេលវេលា ការគ្រប់គ្រងអ្នកជាប់ពន្ធតាមរបបមៅការនៅមានកម្រិត ការមិនបានបញ្ចូលមូលដ្ឋានអាជីវកម្ម ដែលមានផលរបរសមស្របទៅក្នុងរបបស្វ័យប្រកាសឱ្យបានទាន់ពេលវេលា ការគ្រប់គ្រងប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់នៅមានកម្រិត ការបន្សល់ទុកនូវបំណុលពន្ធត្រូវទារជាច្រើន ការមិនបានបង្កើតក្រុមការងារតាមដានការសាងសង់ ជួសជុល ការមិនបានធ្វើសេចក្តីប្រកាសក្រមសីលធម៌វិជ្ជាជីវៈ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ...។

ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៅតែមានបញ្ហាគួរឱ្យកត់សម្គាល់ គឺរហូតមកដល់បច្ចុប្បន្ន ទោះបីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុធ្លាប់បានចេញប្រកាស និងសារាចរណែនាំច្រើនរំលឹកជាញឹកញាប់យ៉ាងណាក៏ដោយ ក៏ក្រសួង-ស្ថាប័ន និងសាលារាជធានី-ខេត្តមួយចំនួននៅតែមានភាពយឺតយ៉ាវ និងខកខានក្នុងការផ្ញើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងប័ណ្ណសម្គាល់កម្មសិទ្ធិលើទ្រព្យសម្បត្តិ។

# ១.សេចក្តីផ្តើម

## ១.១.លក្ខណៈទូទៅ

ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា តម្រូវឱ្យអាជ្ញាធរសវនកម្មជាតិមានភារកិច្ចអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល មានការធ្វើសវនកម្មលើកិច្ចបញ្ជីកាគណនេយ្យ គណនីប្រព័ន្ធគ្រប់គ្រង ការត្រួតពិនិត្យកិច្ចប្រតិបត្តិការ និងកម្មវិធីរបស់បណ្តាក្រសួង ស្ថាប័ន ភ្នាក់ងារ អាជ្ញាធរ ធនាគារជាតិ ស្ថាប័នហិរញ្ញវត្ថុរដ្ឋ និងស្ថាប័នហិរញ្ញវត្ថុចម្រុះឯកជន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ទំនិញ និងសេវាកម្មចំពោះរាជរដ្ឋាភិបាលតាមកិច្ចសន្យា និងបណ្តាអង្គការផ្សេងៗទៀតដែលរាជរដ្ឋាភិបាលបានផ្តល់ជំនួយហិរញ្ញវត្ថុបន្ថែមលើទុនផ្ទាល់ និងឥណទាន រួមមានទាំងការលើកលែងពន្ធអាករគ្រប់ប្រភេទ ព្រមទាំងសម្បទានផ្សេងៗទៀតទៅអង្គការដែលមិនរកប្រាក់ចំណេញ និងសហគ្រាសវិនិយោគឯកជន...។

ក្រៅពីការងារខាងលើនេះ អាជ្ញាធរសវនកម្មជាតិមានភារកិច្ចធ្វើសវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ និងត្រូវធ្វើរបាយការណ៍សវនកម្មជូនទៅរដ្ឋសភា ព្រឹទ្ធសភាដោយផ្ទាល់ និងផ្ញើជូនទៅរាជរដ្ឋាភិបាល ដើម្បីជ្រាបជាព័ត៌មាន ព្រមទាំងផ្សព្វផ្សាយនូវលទ្ធផលសវនកម្មដែលចាំបាច់។

## ១.២.ការអនុវត្ត និងដែនកំណត់សវនកម្ម

ចាប់តាំងពីអាជ្ញាធរសវនកម្មជាតិ បានដំណើរការការងារនៅចុងឆ្នាំ២០០១ រហូតមកដល់ឆ្នាំ២០១១ អាជ្ញាធរសវនកម្មជាតិបានអនុវត្តភារកិច្ចធ្វើសវនកម្ម នៅតាមបណ្តាក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ គម្រោង និងសម្បទានវិនិយោគផ្សេងៗ ព្រមទាំងបានធ្វើរបាយការណ៍សរុបមានចំនួន ៥៥៩ ជាពិសេសគឺការធ្វើសវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ។ ដោយឡែក សម្រាប់ការិយបរិច្ឆេទ២០១១ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្ម និងរៀបចំរបាយការណ៍សរុបមានចំនួន ៣៥ ដែលខ្លឹមសារសំខាន់ៗមួយចំនួនក្នុងរបាយការណ៍ទាំងនោះ ត្រូវបានដកស្រង់មកបង្ហាញក្នុងចំណុចទី៣ នៃរបាយការណ៍សម្រាប់ផ្សព្វផ្សាយជាសាធារណៈនេះ។

អាជ្ញាធរសវនកម្មជាតិ ធ្វើសវនកម្មដោយអនុលោមតាមស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ដែលតម្រូវឱ្យមានការរៀបចំផែនការ និងអនុវត្តការងារសវនកម្មដោយផ្អែកលើមូលដ្ឋាននៃការត្រួតពិនិត្យ វាយតម្លៃលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុលោមតាមបទប្បញ្ញត្តិ និងកិច្ចប្រតិបត្តិការការងាររបស់ក្រសួង-ស្ថាប័នអង្គភាពពាក់ព័ន្ធនានា ព្រមទាំងការធ្វើតេស្តលើឯកសារផ្សេងៗ ដើម្បីទទួលបានភស្តុតាងសវនកម្មសមស្រប សម្រាប់ធ្វើសេចក្តីសន្និដ្ឋាន និងផ្តល់អនុសាសន៍កែលម្អដល់អង្គភាពរងសវនកម្មទាំងនោះ ។

### ១.៣. គោលបំណងនៃការផ្សព្វផ្សាយ

ការផ្សព្វផ្សាយរបាយការណ៍សវនកម្មជាសាធារណៈ មានគោលបំណងចូលរួមចំណែកជាមួយស្ថាប័ននីតិប្បញ្ញត្តិ និងនីតិ-ប្រតិបត្តិ ពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចប្រតិបត្តិ-ការការងាររបស់ក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានា តាមរយៈការចង្អុលបង្ហាញនូវចំណុចខ្វះខាតក្នុងការអនុវត្តកន្លងមក និងផ្តល់អនុសាសន៍កែលម្អលើចំណុចខ្វះខាតទាំងនោះ សំដៅធ្វើឱ្យការគ្រប់គ្រងកាន់តែប្រសើរឡើង។

អាជ្ញាធរសវនកម្មជាតិ មិនទទួលខុសត្រូវអំពីផលប៉ះពាល់ណាមួយចំពោះក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន ក្រុមហ៊ុន-សហគ្រាស ឬបុគ្គលពាក់ព័ន្ធនានា ក្នុងករណីដែលមានតតីយជនទាំងឡាយណា យកខ្លឹមសារក្នុងរបាយការណ៍ផ្សព្វផ្សាយជាសាធារណៈនេះទៅធ្វើការបកស្រាយ ឬប្រើប្រាស់ខុសគោលដៅ។

## ២. ការគ្រប់គ្រងថវិកា

### ២.១. មូលដ្ឋានគតិយុត្តនៃការអនុវត្តថវិកា

កិច្ចដំណើរការនៃថវិកាឆ្នាំ២០១១នេះ ត្រូវបានប្រព្រឹត្តទៅដោយផ្អែកលើមូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួន ដែលមានជាអាទិ៍ ៖

-ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ។

-ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ។

-ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១១ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១០/០១៧ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១០។

-ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ ។

-ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១។

-ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ។

-អនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ។

-អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ២.២.កិច្ចប្រតិបត្តិការថវិកា

កិច្ចប្រតិបត្តិការថវិកាឆ្នាំ២០១១ ត្រូវបានរៀបចំឡើងដោយផ្អែកតាមលទ្ធផលនៃការអនុវត្តចំណូល-ចំណាយតាមរយៈរតនាគារជាតិ រតនាគាររាជធានី-ខេត្ត និងលទ្ធផលនៃការអនុវត្តគម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស ដែលអនុវត្តក្រៅរតនាគារជាតិ ដូចមានបង្ហាញក្នុងតារាងខាងក្រោម៖

### ក/ កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

*ឯកតា : លានរៀល*

| បរិយាយ | អនុវត្ត ២០១០ | ២០១១ | | |
|---|---|---|---|---|
| | | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3* | *4 = (3/2)* |
| **I. សរុបចំណូល** | **9.529.145,9** | **9.849.652,0** | **10.071.358,8** | **102,3%** |
| -ចំណូលចរន្ត | 5.812.516,3 | 6.499.652,0 | 6.370.103,2 | 98,0% |
| -ចំណូលមូលធនក្នុងប្រទេស | 129.917,4 | 57.000,0 | 76.544,3 | 134,3% |
| -មូលនិធិទ្រទ្រង់ថវិកា | 166.283,6 | 342.450,0 | 222.019,5 | 64,8% |
| -ប្រើប្រាស់ប្រាក់បញ្ញើរាជរដ្ឋាភិបាល | - | 350.550,0 | - | - |
| -ចំណូលមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស | 3.420.428,6 | 2.600.000,0 | 3.402.691,8 | 130,9% |
| **II. សរុបចំណាយ** | **9.937.162,5** | **9.849.652,0** | **10.694.383,6** | **108,6%** |
| -ចំណាយចរន្ត | 5.052.480,4 | 5.504.652,0 | 5.784.314,7 | 105,1% |
| -ចំណាយមូលធន | 1.464.253,5 | 1.745.000,0 | 1.507.377,1 | 86,4% |
| -ចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស | 3.420.428,6 | 2.600.000,0 | 3.402.691,8 | 130,9% |

ខ/ កិច្ចប្រតិបត្តិការថវិការាជធានី ខេត្ត

*ឯកតា : លានរៀល*

| បរិយាយ | អនុវត្ត ២០១០ | ២០១១ | | |
|---|---|---|---|---|
| | | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3* | *4 = (3/2)* |
| **I. សរុបចំណូល** | **459.776** | **357.583** | **634.954** | **177,6%** |
| -ចំណូលចរន្ត | 294.232 | 261.907 | 410.522 | 156,7% |
| +ចំណូលសារពើពន្ធ | 260.095 | 239.561 | 384.861 | 160,7% |
| +ចំណូលមិនមែនសារពើពន្ធ | 34.137 | 22.346 | 25.661 | 114,8% |
| -ឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | 165.544 | 95.676 | 224.432 | 234,6% |
| **II. សរុបចំណាយ** | **404.647** | **357.583** | **472.984** | **132,3%** |
| -ចំណាយចរន្ត | 282.697 | 297.156 | 364.059 | 122,5% |
| -ចំណាយមូលធន | 121.950 | 60.427 | 108.925 | 180,3% |

# ៣.លទ្ធផលសមិទ្ធកម្ម

## ៣.១.ការគ្រប់គ្រងថវិកាថ្នាក់ជាតិ

### ៣.១.១. ការប្រើប្រាស់ ឬការចេញវិក្កយបត្រឱ្យទៅអតិថិជន

ច្បាប់ស្តីពីសារពើពន្ធ តម្រូវឱ្យមានការប្រើប្រាស់ ឬចេញវិក្កយបត្រចំពោះរាល់កិច្ចការជំនួញរវាងអ្នកជាប់ពន្ធ និងបុគ្គលដទៃទៀត។ ចំពោះវិក្កយបត្រអាករលើតម្លៃបន្ថែម ត្រូវមានចុះលេខរៀងត្រឹមត្រូវឱ្យទៅអ្នកទិញ និងត្រូវមានចុះនិទ្ទេសដូចជាៈ ឈ្មោះ និងលេខចុះបញ្ជីរបស់អ្នកលក់ កាលបរិច្ឆេទចេញវិក្កយបត្រ ឈ្មោះអ្នកទិញ ឬនិយោជិក ឬភ្នាក់ងារអ្នកទិញ បរិមាណ សេចក្តីបរិយាយ និងថ្លៃលក់ទំនិញ ឬសេវា។ ជាងនេះទៅទៀត វិក្កយបត្រសម្រាប់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវមាន

អាសយដ្ឋាន លេខអត្តសញ្ញាណកម្ម «អតប» លេខវិក្កយបត្រ ថ្ងៃខែឆ្នាំចេញវិក្កយបត្រ រាយមុខទំនិញ ឬសេវា បរិមាណ ថ្លៃឯកតា ថ្លៃសរុប គោត្តនាម និងនាមអ្នកចេញវិក្កយបត្រ...។ តាមការធ្វើតេស្តលើការប្រើប្រាស់វិក្កយបត្រសណ្ឋាគារដែលស្ថិតនៅក្នុងវិស័យនៃសកម្មភាពផ្នែកសណ្ឋាគារ ផ្ទះសំណាក់ និងភោជនីយដ្ឋាន អាជ្ញាធរសវនកម្មជាតិបានរកឃើញថា សណ្ឋាគារមួយចំនួនបានប្រើប្រាស់ ឬចេញវិក្កយបត្រឱ្យទៅអតិថិជនដោយពុំទាន់មានលក្ខណៈត្រឹមត្រូវនៅឡើយ ពោលគឺ វិក្កយបត្រគ្មានលេខអត្តសញ្ញាណកម្ម «អតប» គ្មានលេខវិក្កយបត្រ គ្មានគោត្ត-នាម និងនាមអ្នកចេញវិក្កយបត្រ។

ការប្រើប្រាស់ ឬចេញវិក្កយបត្រដោយមិនបានបំពេញព័ត៌មានច្បាស់លាស់ ពុំអាចបញ្ជាក់បានពីភាពត្រឹមត្រូវ និងអាចជះឥទ្ធិពលដល់ការប្រមូលពន្ធ ព្រមទាំងការធ្វើសវនកម្ម។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គួរណែនាំអគ្គនាយកដ្ឋានពន្ធដារឱ្យពង្រឹងយន្តការតាមដាន ត្រួតពិនិត្យ និងជំរុញការប្រើប្រាស់វិក្កយបត្រឱ្យបានសមស្របតាមការកំណត់។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឆ្លើយបំភ្លឺថា អគ្គនាយក-ដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានរៀបចំ និងចែកជូនអ្នកជាប់ពន្ធ នូវសេចក្តីជូនដំណឹងស្តីពីការប្រើប្រាស់វិក្កយបត្ររបស់សហគ្រាសទាំងអស់ ព្រមទាំងបាននឹងបន្តពង្រឹងការត្រួតពិនិត្យ តាមរយៈការធ្វើសវនកម្មលើសហគ្រាសនីមួយៗជាបន្តបន្ទាប់។

### ៣.១.២.របាយការណ៍សវនកម្មរបស់សវនករឯករាជ្យ

សហគ្រាសវិនិយោគទាំងឡាយ ដែលបានធ្វើសកម្មភាពអាជីវកម្ម មានកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំការិយបរិច្ឆេទនីមួយៗរបស់ខ្លួន ជូនសវនករឯករាជ្យសម្រាប់ធ្វើសវនកម្មស្របទៅតាមច្បាប់ ដែលបានកំណត់ចំពោះសហគ្រាសដែលមានលក្ខណៈវិនិច្ឆ័យពីរ ក្នុងចំណោមលក្ខណៈវិនិច្ឆ័យបីគឺ (១) ផលរបរប្រចាំឆ្នាំ សហគ្រាសមានចំនួនចាប់ពីបីពាន់លានរៀលឡើងទៅ (២) ទ្រព្យសកម្មសរុបមានតម្លៃចាប់ពីពីរពាន់លានរៀលឡើងទៅ (៣) និយោជិកបម្រើការងារមានចំនួនចាប់ពីមួយរយនាក់ឡើងទៅ និងរាល់គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយបានចុះឈ្មោះនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ពោលគឺសហគ្រាសដែលមានលក្ខណៈវិនិច្ឆ័យដូចនេះត្រូវមានរបាយការណ៍សវនកម្មនៃសវនករឯករាជ្យ។ ឆ្នាំ២០១១ នាយកដ្ឋានសវនកម្មសហគ្រាស នៃអគ្គនាយកដ្ឋានពន្ធដារបានចុះធ្វើសវនកម្មលើសហគ្រាស ដែលមានលក្ខណៈវិនិច្ឆ័យត្រូវមានរបាយការណ៍សវនកម្មនៃសវនករឯករាជ្យចំនួន១៩០ ឃើញមានសហគ្រាសចំនួន១៦ ពុំមានរបាយការណ៍សវនកម្មនៃសវនករឯករាជ្យនោះឡើយ។

ប្រការដែលក្រុមហ៊ុនមានលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់ តែមិនមានរបាយការណ៍សវនកម្មនៃសវនករឯករាជ្យ អាចបង្កឱ្យមានការលំបាកដល់ការអនុវត្តមុខងារសវនកម្មរបស់សវនករពន្ធដារ ហើយរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសអាចខ្វះ

នូវភាពជឿជាក់។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរពង្រឹងការគ្រប់គ្រង និងមានវិធានការម៉ឺងម៉ាត់ចំពោះការខកខានអនុវត្តកាតព្វកិច្ចរបស់សហគ្រាសក្នុងការដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់ធ្វើសវនកម្មគណនេយ្យសហគ្រាស។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឆ្លើយបំភ្លឺថា ក្រសួងទទួលយកអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ ហើយបន្តខិតខំពង្រឹងការអនុវត្ត ស្តីពីកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់ការធ្វើសវនកម្មគណនេយ្យសហគ្រាសឱ្យកាន់តែមានប្រសិទ្ធភាព។

**៣.១.៣.យន្តការនៃការធ្វើសវនកម្មសហគ្រាស**

នាយកដ្ឋានសវនកម្មសហគ្រាសមានតួនាទីប្រមូលព័ត៌មាន ស្ថិតិ និងទិន្នន័យរបស់អ្នកជាប់ពន្ធ នាយកដ្ឋានថ្នាក់កណ្តាល អង្គភាពមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធផ្សេងៗ ដើម្បីកំណត់ហានិភ័យសម្រាប់រៀបចំកសាងកម្មវិធីសវនកម្ម និងរៀបចំផែនការសវនកម្មលើសំណុំឯកសារនីមួយៗ និងពិនិត្យសំណុំឯកសារឡើងវិញ ដើម្បីរកឱ្យឃើញបញ្ហាដែលពាក់ព័ន្ធនឹងសំណុំឯកសារនោះ។ ក្នុងការអនុវត្តជាក់ស្តែង នាយកដ្ឋានសវនកម្មសហគ្រាសបានជ្រើសរើសអ្នកជាប់ពន្ធ ដាក់ក្នុងកម្មវិធីសវនកម្ម និងធ្វើសវនកម្មលើអ្នកជាប់ពន្ធ ចំពោះការកំណត់ហានិភ័យរបស់អ្នកជាប់ពន្ធទាក់ទងទៅលើការរៀបចំផែនការ និងការពិនិត្យសំណុំឯកសារឡើងវិញ ពុំទាន់បានល្អប្រសើរនៅឡើយពោលគឺនៅខ្វះព័ត៌មានដូចជាៈ យុទ្ធសាស្ត្រសវនកម្ម ការកំណត់

គោលដៅ និងវិធីសាស្ត្រសវនកម្ម (ការកំណត់ប្រភេទ និងវិសាលភាពនៃការធ្វើតេស្តក្នុងការកាត់បន្ថយហានិភ័យ) និងខ្វះព័ត៌មានរបស់អ្នកជាប់ពន្ធ ។

ប្រការដែលទទួលព័ត៌មានមិនបានពេញលេញ និងទាន់ពេលវេលា អាចនាំឱ្យការកំណត់ហានិភ័យ យុទ្ធសាស្ត្រសវនកម្ម គោលដៅ និងវិធីសាស្ត្រសវនកម្មជួបនូវផលវិបាក ហើយគុណភាពនៃការធ្វើសវនកម្មសហគ្រាសអាចនៅមានកម្រិត។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំអគ្គនាយកដ្ឋានពន្ធដារ និងអង្គភាពប្រតិបត្តិពាក់ព័ន្ធធ្វើការប្រមូលព័ត៌មាន ស្ថិតិ និងទិន្នន័យរបស់អ្នកជាប់ពន្ធឱ្យបានពេញលេញ និងទាន់ពេលវេលា ដើម្បីរៀបចំផែនការ និងការធ្វើសវនកម្មឱ្យបានល្អប្រសើរ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឆ្លើយបំភ្លឺថា ក្រសួងឯកភាពតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។ អគ្គ-នាយកដ្ឋានពន្ធដារ បាន និងកំពុងរៀបចំប្រព័ន្ធព័ត៌មានវិទ្យា ដែលនឹងអាចតភ្ជាប់បណ្ដាញអង្គភាពផ្ទៃក្នុង នៃអគ្គនាយកដ្ឋានពន្ធដារ និងស្ថាប័នរដ្ឋដទៃទៀត ដើម្បីប្រមូលព័ត៌មាន និងគាំទ្រការរៀបចំកម្មវិធីធ្វើសវនកម្ម ។

**៣.១.៤. ការគ្រប់គ្រងចំណូលពីប្រាក់វិភាគទាន០,៥% នៃបុព្វ-លាភធុល**

គោលការណ៍នៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋ រាល់ការអនុវត្តចំណូល-ចំណាយថវិការដ្ឋ ត្រូវស្ថិតនៅក្រោមបញ្ញត្តិនៃច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលចំណូលត្រូវកត់

គ្រាចូលទាំងស្រុង ហើយមិនត្រូវយកទៅកាត់កងដោយត្រង់ជាមួយចំណាយឡើយ។ ទន្ទឹមនឹងនេះដែរ អនុក្រឹត្យស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈបានបញ្ជាក់ថា ចំណូលត្រូវបានគិតចូលក្នុងថវិកានៃឆ្នាំ ដែលក្នុងអំឡុងនោះ ចំណូលទាំងនោះត្រូវបានប្រមូលដោយគណនេយ្យករសាធារណៈ....។ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានប្រមូលប្រាក់ភាគទាន០,៥% នៃបុព្វលាភផុលពីក្រុមហ៊ុនធានារ៉ាប់រងចន្លោះឆ្នាំ២០០៣-២០១១ មានចំនួនទឹកប្រាក់សរុបប្រមាណ ៧៦៧.០០០ ដុល្លារអាមេរិក (ប្រាំពីររយហុកសិបប្រាំពីរពាន់ដុល្លារអាមេរិក) ទឹកប្រាក់ចំនួនប្រមាណ ៨៥.០០០ ដុល្លារអាមេរិក (ប៉ែតសិបប្រាំពាន់ដុល្លារអាមេរិក) ត្រូវបាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុដកយកទៅចំណាយផ្សេងៗ ដោយពុំមានកត់ត្រាចូលក្នុងថវិការដ្ឋនោះឡើយ រីឯ ប្រាក់នៅសល់ប្រមាណ ៦៨១.០០០ ដុល្លារអាមេរិក (ប្រាំមួយរយប៉ែតសិបមួយពាន់ដុល្លារអាមេរិក) ត្រូវបានរក្សាទុកនៅក្នុងគណនីនៃធនាគារមួយ ដោយពុំទាន់បានបង្វែរចូលថវិការដ្ឋនៅឡើយ។

ការមិនបានបង់ចំណូលចូលថវិកាឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលា នាំឱ្យការអនុវត្តច្បាប់មិនបានពេញលេញ និងនាំឱ្យស្ថានភាពចំណូល-ចំណាយថវិកាទូទៅមិនឆ្លុះបញ្ចាំងពីសភាពជាក់ស្តែង ព្រមទាំងអាចជះឥទ្ធិពលមិនល្អដល់ការគ្រប់គ្រងហិរញ្ញវត្ថុ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គួរណែនាំ

នាយកដ្ឋាននិស្សាហកម្មហិរញ្ញវត្ថុ អនុវត្តការបង់ចំណូលចូលថវិកាឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំភ្លឺថា ប្រាក់វិភាគទាន ០.៥% មិនមែនជាចំណូលរបស់រដ្ឋទេ គឺជាមូលនិធិបរធនរបស់ក្រុមហ៊ុនធានារ៉ាប់រងសម្រាប់អភិវឌ្ឍន៍វិស័យធានារ៉ាប់រង ដូចបណ្តាប្រទេសលើពិភពលោក បាន និងកំពុងអភិវឌ្ឍក្នុងគោលដៅរក្សានូវសុវត្ថិភាពសង្គម និងនិរន្តភាពនៃវិស័យធានារ៉ាប់រង។ មូលនិធិនេះ នឹងត្រូវប្រើប្រាស់សម្រាប់អន្តរាគមន៍ពេលមានវិបត្តិវិស័យធានារ៉ាប់រងដោយមិនប្រើប្រាស់ថវិការដ្ឋ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមបញ្ជាក់ថា នៅពេលច្បាប់ស្តីពីការធានារ៉ាប់រងដែលគ្រោងនឹងអនុម័តនៅឆ្នាំ ២០១២ ឬឆ្នាំ២០១៣ ខាងមុខនេះ និងអនុក្រឹត្យស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុចូលជាធរមាន មូលនិធិនេះនឹងត្រូវផ្ទេរឱ្យមានការគ្រប់គ្រងដោយឡែកតាមការចង្អុលរបស់ច្បាប់ និងបទបញ្ញាជាធរមាន និងអនុវត្តតាមស្តង់ដារអន្តរជាតិផងដែរ។

### ៣.១.៥.ការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ

នៅដើមឆ្នាំ២០១០កន្លងទៅនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មទទួលបញ្ចាំ និងទិញ លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគ ដោយអនុប្បទានរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលបានបញ្ជាក់ថា ក្រសួងនឹងផ្តល់អាជ្ញាប័ណ្ណជូនដល់អាជីវករទាំងឡាយ

ណាដែលបានបំពេញលក្ខខណ្ឌដូចជា មានកម្រិតវប្បធម៌ចាប់ពីថ្នាក់បរិញ្ញាប័ត្រ ឬប្រហាក់ប្រហែលផ្នែកសេដ្ឋកិច្ច ឬពាណិជ្ជកម្ម ឬនីតិសាស្ត្រ វិញ្ញាបនប័ត្រផ្សេងៗទៀតដែលទាក់ទងនឹងអាជីវកម្ម ឬមានបទពិសោធន៍ពាក់ព័ន្ធ ទៅនឹងការគ្រប់គ្រងផ្នែកអាជីវកម្ម ឬធ្លាប់បម្រើការងារផ្នែកនេះពីមុន។ ផ្ទុយទៅវិញ ក្រសួងនឹងមិនផ្តល់អាជ្ញាប័ណ្ណប្រកបអាជីវកម្មជូនអ្នកដាក់ពាក្យស្នើសុំអាជ្ញា-ប័ណ្ណទាំងឡាយណា ដែលមិនបានផ្តល់ព័ត៌មានដែលខ្វះចន្លោះណាមួយដូចមានចែងក្នុងលក្ខខណ្ឌខាងលើនេះទេ។ ប៉ុន្តែតាមការធ្វើតេស្តលើឯកសារស្នើសុំអាជ្ញាប័ណ្ណរបស់អាជីវករចំនួន ២០ ក្នុងចំណោមអាជ្ញាប័ណ្ណ ៨៦ ដែលធ្វើអាជីវកម្មទទួលបញ្ចាំនិងទិញ លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគ ដោយអនុប្បទានបញ្ចាំដែលត្រូវបានផ្តល់ឱ្យដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងឆ្នាំ២០១១ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានឯកសារស្នើសុំអាជ្ញាប័ណ្ណចំនួន១៧ មិនបានភ្ជាប់មកជាមួយនូវឯកសារគ្រប់គ្រាន់ ដូចជា៖ ឯកសារពាក់ព័ន្ធនឹងកម្រិតវប្បធម៌ចាប់ពីថ្នាក់បរិញ្ញាប័ត្រ ឬប្រហាក់ប្រហែលផ្នែកសេដ្ឋកិច្ច ឬពាណិជ្ជកម្ម ឬនីតិសាស្ត្រ វិញ្ញាបនប័ត្រផ្សេងៗទៀតដែលទាក់ទងនឹងអាជីវកម្ម ឬមានបទពិសោធន៍ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងផ្នែកអាជីវកម្ម ឬធ្លាប់បម្រើការងារផ្នែកនេះពីមុន។

ប្រការដែលអាជីវករមិនបានបំពេញលក្ខខណ្ឌ ឬលក្ខណៈគ្រប់គ្រាន់ អាចនាំឱ្យការគ្រប់គ្រងអាជីវកម្មនេះពុំបានគ្រប់ជ្រុង

ជ្រាយ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរពិនិត្យមើលភាពគ្រប់គ្រាន់នៃសំណុំឯកសារ ចំពោះការស្នើសុំអាជ្ញាប័ណ្ណប្រកបអាជីវកម្មដែលក្រសួងបានកំណត់ មុននឹងចេញអាជ្ញាប័ណ្ណជូនទៅអាជីវករ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលើកហេតុផលថា ថ្វីត្បិតតែអ្នកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ ពុំមានកម្រិតវប្បធម៌ចាប់ពីថ្នាក់បរិញ្ញាបត្រក៏ដោយ ក៏អ្នកទាំងនោះមានបទពិសោធន៍ជាច្រើនឆ្នាំ និងមានជំនាញខ្ពស់ក្នុងការត្រួតពិនិត្យវាយតម្លៃលើវត្ថុដាក់បញ្ចាំដែលមានមូលដ្ឋានចាំបាច់ក្នុងការប្រកបធុរៈកិច្ចរបស់ខ្លួន ដែលចំណុចនេះស្របនឹងលក្ខខណ្ឌតម្រូវការស្នើសុំអាជ្ញាប័ណ្ណ ដូចមានចែងស្តីពីការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មបញ្ចាំ និងទិញទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន។ តទៅមុខទៀត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុខិតខំអនុវត្តឱ្យបានកាន់តែល្អតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។

### ៣.១.៦.ការផ្ញើរបាយការណ៍អាជីវកម្មអភិវឌ្ឍអចលនវត្ថុទៅក្រុមការងារអន្តរក្រសួង

ប្រកាសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ ក្នុងគោលបំណងទប់ស្កាត់រាល់ការអភិវឌ្ឍន៍អចលនវត្ថុដែលគ្មានភាពច្បាស់លាស់ និងគ្មានការអនុញ្ញាតត្រឹមត្រូវ និងបង្កើនប្រាក់ចំណូលជាតិតាមរយៈការយកពន្ធអាករ និងការបង់ថ្លៃសេវាផ្សេងៗបានបញ្ជាក់ថា បុគ្គល

អភិវឌ្ឍអចលនវត្ថុ ត្រូវផ្តល់របាយការណ៍ស្តីពីការអភិវឌ្ឍអចលនវត្ថុ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសឱ្យទៅក្រុមការងារអន្តរក្រសួងឱ្យបានមុនថ្ងៃទី១៥ ខែទី១ ត្រីមាសបន្ទាប់ ដោយត្រូវបញ្ជាក់ថា ពិត និងត្រឹមត្រូវ។ ក្រោយពីបញ្ចប់គម្រោងអភិវឌ្ឍអចលនវត្ថុ ឬចុងឆ្នាំនៃគម្រោងនីមួយៗយ៉ាងយូរ ០៣ខែ បុគ្គលអភិវឌ្ឍអចលនវត្ថុ ត្រូវផ្តល់ឱ្យក្រុមការងារអន្តរក្រសួងនូវរបាយ-ការណ៍ស្តីពីការអភិវឌ្ឍន៍អចលនវត្ថុ និងរបាយការណ៍ហិរញ្ញវត្ថុនៃគម្រោង ឬឆ្នាំសារពើពន្ធកន្លងមក ដែលត្រូវបានត្រួតពិនិត្យដោយសវនករគណនេយ្យឯករាជ្យណាមួយ ដោយមានការទទួលស្គាល់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ប៉ុន្តែក្នុងឆ្នាំ ២០១១ បុគ្គលអភិវឌ្ឍអចលនវត្ថុមិនបានផ្តល់របាយការណ៍ស្តីពីការអភិវឌ្ឍន៍អចលនវត្ថុ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស និងរបាយការណ៍ហិរញ្ញវត្ថុនៃគម្រោងដែលត្រូវបានត្រួតពិនិត្យដោយសវនករគណនេយ្យឯករាជ្យឱ្យទៅក្រុមការងារអន្តរក្រសួងនោះទេ។

ករណីខ្វះចន្លោះនេះ អាចនាំឱ្យការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុពុំបានច្បាស់លាស់។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរពង្រឹងការគ្រប់គ្រង និងមានវិធានការជំរុញបុគ្គលអភិវឌ្ឍអចលនវត្ថុទាំងអស់ឱ្យផ្តល់របាយការណ៍ស្តីពីការអភិវឌ្ឍអចលនវត្ថុ និងរបាយការណ៍ហិរញ្ញវត្ថុនៃគម្រោងឱ្យបានទៀងទាត់ និងទាន់ពេលវេលា ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានធ្វើការបំភ្លឺថា ការមិនបានធ្វើរបាយការណ៍របស់បុគ្គលអភិវឌ្ឍអចលនវត្ថុបណ្តាលមកពីវិស័យអចលនទ្រព្យទើបងើបចេញពីវិបត្តិហិរញ្ញវត្ថុសកលក្រុមហ៊ុនមួយចំនួនធំ ទើបតែចាប់ផ្តើមដំណើរការឡើងវិញដោយពុំទាន់មានសកម្មភាពទិញលក់ធំដុំនៅឡើយ។ ម្យ៉ាងវិញទៀតនៅពេលនោះ គឺកំពុងតែស្ថិតក្នុងដំណាក់កៀរគរ និងលើកទឹកចិត្តឱ្យបុគ្គលអភិវឌ្ឍអចលនវត្ថុ ដែលគ្មានអាជ្ញាប័ណ្ណមកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណឱ្យបានគ្រប់ៗគ្នា ប៉ុន្តែពុំមែនជាការលើកលែងរហូតនោះទេ។ បច្ចុប្បន្ន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏ដូចជានាយកដ្ឋាន និងការិយាល័យជំនាញកំពុងកែសម្រួលគំរូរបាយការណ៍ដ៏រសើបនេះ ហើយនឹងដាក់ជូនក្រុមការងារអន្តរក្រសួងពិនិត្យ និងសម្រេច ដើម្បីចាប់ផ្តើមអនុវត្តក្នុងពេលឆាប់ៗខាងមុខនេះ។

### ៣.១.៧. ការធ្វើ និងការផ្ញើផែនការលទ្ធកម្មប្រចាំឆ្នាំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យស្តីពីលទ្ធកម្មសាធារណៈដោយបានកំណត់ថា ស្ថាប័នអនុវត្តលទ្ធកម្មត្រូវធ្វើផែនការលទ្ធកម្មប្រចាំឆ្នាំរបស់ខ្លួនដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីពិនិត្យ និងអនុម័តនៅដើមឆ្នាំសារពើពន្ធនីមួយៗ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏បានដាក់ចេញសារាចរណែនាំស្តីពីការរៀបចំផែនការលទ្ធកម្មឆ្នាំ២០០៨ និងឆ្នាំបន្តបន្ទាប់ ដោយបានបញ្ជាក់ថា ប្រធានស្ថាប័នអនុវត្តលទ្ធកម្មត្រូវពិនិត្យ និងអនុម័តលើផែនការលទ្ធកម្មរបស់ខ្លួន រួចផ្ញើទៅក្រសួងសេដ្ឋកិច្ច និង

ហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមសប្ដាហ៍ទី១ ខែមករា នៃឆ្នាំសារពើ-ពន្ធ។ ប៉ុន្តែក្នុងឆ្នាំ២០១១ ក្រសួង-ស្ថាប័ន រាជធានី-ខេត្ត និងសហគ្រាសសាធារណៈមួយចំនួន មានការយឺតយ៉ាវក្នុងការធ្វើផែនការលទ្ធកម្ម និងមិនបានផ្ញើផែនការលទ្ធកម្មប្រចាំឆ្នាំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឡើយ។

ការមិនបានរៀបចំផែនការលទ្ធកម្មឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា អាចនាំឱ្យការគ្រប់គ្រងផែនការលទ្ធកម្ម និងឱ្យការអនុវត្តចំណាយថវិកាប្រព្រឹត្តទៅមិនស្របតាមទិសដៅ និងអាចខ្វះតម្លាភាព។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំក្រសួង-ស្ថាប័ន និងសហគ្រាសសាធារណៈពង្រឹងការអនុវត្តតាមអនុក្រឹត្យរបស់រាជរដ្ឋាភិបាល និងសារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទទួលស្គាល់ថា ពិតជានៅមានស្ថាប័នអនុវត្តលទ្ធកម្មមួយចំនួនតូចមិនបានធ្វើផែនការលទ្ធកម្ម និងស្ថាប័នអនុវត្តលទ្ធកម្មមួយចំនួនផ្សេងទៀតមានការយឺតយ៉ាវក្នុងការផ្ញើផែនការលទ្ធកម្មមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីពិនិត្យ និងអនុម័ត។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាពទៅនឹងអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ ដោយបានដោះស្រាយបញ្ហានេះតាមរយៈ៖ (១) រៀងរាល់ពាក់កណ្ដាលត្រីមាសទី៤ នៃឆ្នាំនីមួយៗ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអញ្ជើញប្រធានអង្គភាពលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្មប្រជុំណែនាំអំពីរបៀបនៃការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ។

បន្ទាប់ពីការប្រជុំណែនាំនេះ នាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានអញ្ជើញប្រធានអង្គភាពលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្មម្តងមួយៗមកប្រជុំពិភាក្សាលើសេចក្តីព្រាងផែនការលទ្ធកម្មរបស់ស្ថាប័នអនុវត្តលទ្ធកម្មនោះ

(២) ចាប់ពីឆ្នាំ២០១៣ តទៅ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងមិនផ្តល់ការចំណាយ (គោលការណ៍ធានាចំណាយ) ដល់ស្ថាប័នអនុវត្តលទ្ធកម្មណាដែលមិនបានផ្ញើផែនការលទ្ធកម្មមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងអនុម័តមុនថ្ងៃទី៣១ធ្នូ នៃឆ្នាំសារពើពន្ធនោះទេ។

**៣.១.៨. ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ**

តាមគោលការណ៍នៃកិច្ចលទ្ធកម្មសាធារណៈ ក្រសួង-ស្ថាប័ន និងរាជធានី-ខេត្តត្រូវរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំរបស់ខ្លួន ដើម្បីដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិនិត្យ និងអនុម័តនៅដើមឆ្នាំសារពើពន្ធនីមួយៗ។ រាល់គម្រោងចំណាយដែលត្រូវអនុវត្តវិធីសាស្ត្រលទ្ធកម្មសាធារណៈត្រូវកត់បញ្ចូលក្នុងផែនការលទ្ធកម្ម។ ការរៀបចំផែនការលទ្ធកម្មត្រូវផ្អែកតាមទម្រង់ដែលកំណត់ក្នុងការអនុវត្តវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ។ ស្ថាប័នអនុវត្តលទ្ធកម្មសាធារណៈត្រូវអនុវត្តកិច្ចលទ្ធកម្មឱ្យបានទៀងទាត់តាមកម្មវិធី ដែលបានកំណត់ក្នុងផែនការលទ្ធកម្ម។ ជាក់ស្តែង សាមីក្រសួង-ស្ថាប័ន និងបណ្តាអង្គភាពនៅតាមរាជធានី-ខេត្ត ដែលជាស្ថាប័នអនុវត្តលទ្ធកម្មសាធារណៈមួយចំនួនបានអនុវត្តកិច្ចលទ្ធកម្មរបស់ខ្លួនលើសពី

គម្រោងផែនការដែលបានអនុម័ត ដោយការងារលទ្ធកម្មដែលបានអនុម័តសម្រាប់ឆ្នាំ២០១១ សរុបទាំងក្រសួង-ស្ថាប័ន និងរាជធានី-ខេត្តមានចំនួន២.០៥៥គម្រោង (ការដេញថ្លៃដោយ ប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ ការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក ពិគ្រោះថ្លៃ ស្ទង់តម្លៃ និងចរចាថ្លៃ) ប៉ុន្តែបានអនុវត្តរហូតដល់ទៅ៣.១០៨គម្រោង។

ការអនុវត្តលទ្ធកម្មមិនស្របតាមផែនការ និងនីតិវិធីលទ្ធកម្មសាធារណៈនឹងអាចបង្កការពិបាកក្នុងការទូទាត់ បំបែកគម្រោងលទ្ធកម្មសាធារណៈ ចំណាយខ្វះតម្លាភាព។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គួរណែនាំសាមីក្រសួង-ស្ថាប័ន រាជធានី-ខេត្តអនុវត្តការចំណាយលទ្ធកម្មឱ្យស្របតាមផែនការលទ្ធកម្មដែលបានអនុម័ត។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំភ្លឺថា បញ្ហានេះពិតជាមានស្ថាប័នអនុវត្តលទ្ធកម្មមួយចំនួនបានអនុវត្តកិច្ចលទ្ធកម្មលើសពីគម្រោងរបស់ខ្លួន ដែលបានអនុម័តក្នុងផែនការលទ្ធកម្ម។ កត្តាដែលនាំឱ្យកើតឡើងនូវបញ្ហានេះរួមមាន៖ (១) ស្ថាប័នអនុវត្តកិច្ចលទ្ធកម្មមួយចំនួនមិនត្រូវបានតម្រូវឱ្យកត់ត្រាចូលក្នុងផែន-ការលទ្ធកម្មចំពោះគ្រប់គម្រោង ដែលត្រូវអនុវត្តវិធីសាស្ត្រលទ្ធកម្មដោយឡែក (ចរចាថ្លៃ) ដោយសារមានគោលការណ៍ពីរាជរដ្ឋាភិបាលរួចហើយ (២) ស្ថាប័នអនុវត្តលទ្ធកម្មមួយចំនួនបានទទួលឥណទានបន្ថែមពីលើឥណទានឆ្នាំ ឬសល់ឥណទានមួយចំនួនពីការដេញថ្លៃរួចរៀបចំដេញថ្លៃបន្ថែមទៀត (៣) ស្ថាប័ន

អនុវត្តលទ្ធកម្មមួយចំនួន ពិសេសរាជធានី-ខេត្តបានបំបែកគម្រោងលទ្ធកម្ម ដែលស្ថិតក្រោមសិទ្ធិសម្រេចរបស់ខ្លួន ដើម្បីបំពាននីតិវិធីសាស្ត្រលទ្ធកម្ម។ ដើម្បីដោះស្រាយបញ្ហានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងមានវិធានការ៖ (១) កត់ត្រាចូលក្នុងផែនការលទ្ធកម្ម (ផែនការកែតម្រូវ) (២) ចាប់ពីឆ្នាំ២០១៣តទៅ គ្រប់គម្រោង ដែលត្រូវអនុវត្តវិធីសាស្ត្រលទ្ធកម្ម ដោយឡែក (ចរចាថ្លៃ) ដោយសារមានគោលការណ៍ពីរាជរដ្ឋាភិបាលរួចហើយ ត្រូវកត់ត្រាចូលក្នុងផែនការលទ្ធកម្ម (៣) រាល់គម្រោងដែលទទួលបានពីឥណទានបន្ថែម ឬសល់ពីការដេញថ្លៃត្រូវកត់ត្រាចូលក្នុងផែនការលទ្ធកម្ម (ផែនការកែតម្រូវ) (៤) ពិចារណាកាត់បន្ថយទំហំទឹកប្រាក់សិទ្ធិសម្រេចរបស់ស្ថាប័នអនុវត្តលទ្ធកម្មណា ដែលបំបែកគម្រោងដែលបានអនុម័តរួចហើយ។

## ៣.២. ការគ្រប់គ្រងថវិការាជធានី ខេត្ត

### ៣.២.១.ការប្រមូលពន្ធអចលនទ្រព្យ

គោលការណ៍នៃការប្រមូលពន្ធលើអចលនទ្រព្យ បានតម្រូវឱ្យម្ចាស់អចលនទ្រព្យបំពេញព័ត៌មានអចលនទ្រព្យ ចុះបញ្ជី ដាក់លិខិតប្រកាស និងបង់ពន្ធ។ សម្រាប់ឆ្នាំ២០១១ ការប្រកាសបង់ពន្ធគឺចប់សព្វគ្រប់ត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១១។ ដោយសារការអនុវត្តប្រមូលពន្ធនេះជាការងារថ្មី ហើយម្ចាស់អចលនទ្រព្យមួយចំនួនពុំទាន់យល់ដឹងពីរបៀបបំពេញលិខិតប្រកាសពន្ធ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានពន្យាពេលផុតកំណត់បង់ពន្ធរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ ដែលសម្រេចបាន

ចំនួន១១៣.៨៨៥មូលដ្ឋានជាប់ពន្ធ ស្មើនឹងប្រាក់ពន្ធចំនួន ៥៧.៩៥៤ លានរៀល។ តាមការធ្វើសវនកម្មនៅសាខាពន្ធដារខណ្ឌនៃរាជធានីភ្នំពេញ និងសាខាពន្ធដារខេត្តចំនួន០៧ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការអនុវត្តប្រមូលពន្ធនៅមានកម្រិតនៅឡើយ ដោយអ្នកជាប់ពន្ធមួយចំនួនមិនបានផ្តល់ព័ត៌មានអំពីអចលនទ្រព្យ មិនមកចុះបញ្ជីពន្ធអចលនទ្រព្យ មិនមកប្រកាសបង់ពន្ធលើអចលនទ្រព្យ និងអ្នកជាប់ពន្ធមួយចំនួនបានចុះបញ្ជីពន្ធអចលនទ្រព្យរួចហើយ ប៉ុន្តែមិនព្រមមកបង់ពន្ធ។

ការខកខានក្នុងការអនុវត្តកាតព្វកិច្ចពន្ធរបស់អ្នកជាប់ពន្ធនាំឱ្យការប្រមូលពន្ធលើអចលនទ្រព្យប្រព្រឹត្តទៅពុំទាន់អស់លទ្ធភាព។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គួរណែនាំអគ្គនាយកដ្ឋានពន្ធដារអនុវត្តការចុះបញ្ជីអចលនទ្រព្យឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលា ព្រមទាំងធ្វើការណែនាំដល់ម្ចាស់អចលនទ្រព្យអំពីការបំពេញកាតព្វកិច្ចពន្ធឱ្យបានទូលំទូលាយបន្ថែមទៀត។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំភ្លឺថា មូលដ្ឋានអចលនទ្រព្យដែលមិនទាន់បង់ពន្ធ គឺបណ្តាលមកពីម្ចាស់អចលនទ្រព្យបានដាក់លិខិតប្រកាសធ្វើតាមរយៈភូមិ-ឃុំ-សង្កាត់មកសាខាពន្ធដារខេត្ត-ខណ្ឌមានការយឺតយ៉ាវ ហើយមកទល់ពេលនេះម្ចាស់អចលនទ្រព្យទាំងនោះបានមកបង់ពន្ធរួចរាល់ហើយ។

### ៣.២.២.ការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ

នៅក្នុងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ រាជរដ្ឋាភិបាលបានចេញសារាចរណែនាំដោយបានណែនាំថា ត្រូវយកថវិកាកំពុងប្រព្រឹត្តទៅនៃឆ្នាំធ្វើជាមូលដ្ឋានក្នុងការរៀបចំថវិកាឆ្នាំបន្ទាប់ ដើម្បីធានាឱ្យសេវាសាធារណៈនានាអាចដំណើរការទៅបាន។ តាមការធ្វើសវនកម្មនៅខេត្តចំនួន៥ ក្នុងចំណោមរាជធានី-ខេត្តចំនួន២៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានខេត្តចំនួន៣ បានគ្រោងចំណូលសារពើពន្ធប្រចាំឆ្នាំ ដោយពុំបានលើកយកតួលេខនៃការអនុវត្តថវិកាជាក់ស្តែងឆ្នាំ២០១០ មកធ្វើជាមូលដ្ឋានក្នុងការរៀបចំថវិកាឆ្នាំ២០១១ ឱ្យស្របតាមគោលការណ៍ណែនាំឡើយ។

ការពុំបានលើកយកតួលេខនៃការអនុវត្តថវិកាជាក់ស្តែងឆ្នាំចាស់ធ្វើជាមូលដ្ឋានអាចនាំឱ្យចំណូលស្តែងចេញនូវអត្រាកំណើនខ្ពស់ដែលមិនឆ្លុះបញ្ចាំងពីស្ថានភាពចំណូលជាក់ស្តែង។ សាលាខេត្ត គួររៀបចំគម្រោងថវិកាប្រចាំឆ្នាំបន្ទាប់ដោយគិតបញ្ចូលអំពីតួលេខនៃការអនុវត្តថវិកានៃឆ្នាំឱ្យបានត្រឹមត្រូវ។

សាលាខេត្តបានសន្យាថា នឹងខិតខំអនុវត្តឱ្យបានត្រឹមត្រូវតាមការណែនាំរបស់រាជរដ្ឋាភិបាល។

### ៣.២.៣.ការបង្កើតក្រុមការងារតាមដានការសាងសង់ និងជួសជុល

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានប្រកាសដាក់ឱ្យប្រើប្រាស់សៀវភៅលទ្ធកម្មស្តីពីការអនុវត្តវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ដោយបានបញ្ជាក់ថា ជាទូទៅការត្រួតពិនិត្យ

កិច្ចសន្យាសំណង់មានការស្មុគស្មាញ ដោយសារកត្តាទាំងឡាយដែលមិនអាចដឹងមុនបាន ដូចនេះនៅមុនពេលចាប់ផ្តើមការងារគឺតម្រូវឱ្យមានការចាត់តាំងឱ្យមានអ្នកគ្រប់គ្រងគម្រោង ដើម្បីធ្វើការគ្រប់គ្រងទីតាំងគម្រោង និងត្រួតពិនិត្យសកម្មភាពប្រចាំថ្ងៃរបស់អ្នកទទួលការ។ អ្នកគ្រប់គ្រងគម្រោងត្រូវធ្វើរបាយការណ៍ជាប្រចាំអំពីវឌ្ឍនភាព និងបញ្ហាដែលកើតមានឡើងក្នុងពេលអនុវត្តការងារ។ តាមការធ្វើសវនកម្មលើខេត្តចំនួន៥ អាជ្ញាធរ-សវនកម្មជាតិសង្កេតឃើញថា មានខេត្តចំនួន៣ មិនទាន់បានបង្កើតក្រុមការងារតាមដានការសាងសង់ និងជួសជុលនៅឡើយ។

ប្រការដែលមិនបានបង្កើតក្រុមការងារតាមដាន ការសាងសង់ និងជួសជុលអាចនាំឱ្យសំណង់ពុំធានាបាននូវគុណភាពទៅតាមបទដ្ឋានបច្ចេកទេស។ សាលាខេត្តគួរចាត់តាំងអ្នកគ្រប់គ្រងគម្រោង ដើម្បីឱ្យមានអ្នកទទួលខុសត្រូវតាមដានការងារនេះឱ្យបានហ្មត់ចត់។

សាលាខេត្តបានឆ្លើយតបថា នឹងកែលម្អការងារនេះនាពេលខាងមុខ។

**៣.២.៤.ការធ្វើសេចក្តីប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈ**

ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅលទ្ធកម្មនៃការអនុវត្តវិធាន និងបទ-ប្បញ្ញត្តិលទ្ធកម្មសាធារណៈបានបញ្ជាក់ថា នៅរាល់ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតម្លៃ និងប្រគល់កិច្ចសន្យា និងអ្នកដេញថ្លៃត្រូវធ្វើ

សេចក្ដីប្រកាសស្ដីពីក្រមសីលធម៌វិជ្ជាជីវៈ។ តាមការធ្វើសវនកម្មលើការអនុវត្តកិច្ចលទ្ធកម្មនៅខេត្តចំនួន៥ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញមានខេត្តចំនួន៣ ដែលគណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតម្លៃ និងប្រគល់កិច្ចសន្យា និងអ្នកដេញថ្លៃពុំបានធ្វើសេចក្ដីប្រកាសស្ដីពីក្រមសីលធម៌វិជ្ជាជីវៈស្ដីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ។

ការមិនបានធ្វើសេចក្ដីប្រកាសស្ដីពីក្រមសីលធម៌វិជ្ជាជីវៈអាចនាំឱ្យប៉ះពាល់ដល់ការអនុវត្តគោលការណ៍លទ្ធកម្មសាធារណៈ។ សាលាខេត្ត គួរណែនាំគណៈកម្មាធិការបុរេលក្ខណៈសម្បត្តិ វាយតម្លៃ និងប្រគល់កិច្ចសន្យា និងអ្នកដេញថ្លៃអនុវត្តឱ្យបានត្រឹមត្រូវតាមគោលការណ៍លទ្ធកម្មដែលបានកំណត់។

សាលាខេត្តបានបំភ្លឺថា នឹងនាំយកអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិទៅពិភាក្សាជាមួយនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីដាក់បញ្ចូលក្រមសីលធម៌វិជ្ជាជីវៈរបស់គណៈកម្មការខាងលើ។

## ៤.ការពិនិត្យនៅលើវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍សវនកម្ម

ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០១១ និងនាពេលកន្លងមក អាជ្ញាធរសវនកម្មជាតិកត់សម្គាល់ឃើញថា រាល់ចំណុចខ្វះខាត និងអនុសាសន៍សវនកម្មទាំងឡាយដែលអាជ្ញាធរ-សវនកម្មជាតិបានលើកឡើង ចំណុចមួយចំនួនត្រូវបានក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធ

នានាខិតខំអនុវត្តកែលម្អគួរឱ្យកត់សម្គាល់ និងកោតសសើរ រីឯចំណុចមួយចំនួនទៀតនៅតែបន្តកើតមាននៅឡើយ ជាអាទិ៍ ៖

**៤.១. ការទៅបំពេញកាតព្វកិច្ចចុះបញ្ជីសារពើពន្ធសហគ្រាស៖**

ច្បាប់ស្តីពីសារពើពន្ធសហគ្រាស ក្រោយពីចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មរួចហើយ សហគ្រាសត្រូវរូសកាន់ទៅចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងអំឡុង១៥ថ្ងៃ។ ក្នុងករណីមិនបានទៅចុះបញ្ជីទេនោះ រដ្ឋបាលសារពើពន្ធអាចធ្វើការចុះបញ្ជីចាប់តាំងពីពេលដែលសហគ្រាសត្រូវទៅចុះបញ្ជី ហើយការចុះបញ្ជីបែបនេះសហគ្រាសត្រូវមានការទទួលខុសត្រូវ ចំពោះប្រាក់អាករទាំងអស់ចាប់តាំងពីកាលបរិច្ឆេទដែលបានកំណត់។ ប៉ុន្តែតាមការធ្វើតេស្តសហគ្រាសចំនួន ៣៦៨ ដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មក្នុងឆ្នាំ ២០១១ អាជ្ញាធរសវនកម្មជាតិ រកឃើញថា មានសហគ្រាសចំនួន ២៦៦ បានមកបំពេញកាតព្វកិច្ចចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ រីឯចំនួនសហគ្រាសនៅសល់ពីនេះពុំមានប្រភពបញ្ជាក់ច្បាស់លាស់ឡើយ។

**៤.២. ការប្រកាសពន្ធរបស់សហគ្រាស៖** ការដាក់លិខិតប្រកាសពន្ធអាករប្រចាំខែ ប្រចាំឆ្នាំនៅរដ្ឋបាលសារពើពន្ធត្រូវធ្វើឡើងដោយភាពត្រឹមត្រូវនិងច្បាស់លាស់ ហើយបណ្ណាធិការសហគ្រាសជាអ្នកទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ ប្រសិនបើព័ត៌មានណាមួយមានការក្លែងបន្លំ។ ការធ្វើសវនកម្ម អាជ្ញាធរសវនកម្មសង្កេតឃើញថា មានសហគ្រាសមួយចំនួនបានធ្វើការនាំចូលទំនិញ ប៉ុន្តែបានដាក់លិខិតប្រកាសពន្ធសូន្យ (គ្មានសកម្មភាពអាជីវកម្ម)។ ជាមួយគ្នានេះ

ដែរ មានសហគ្រាសមួយចំនួនផ្សេងទៀតបានដាក់លិខិតប្រកាសពន្ធ ប្រកាសតម្លៃលក់ទាបជាងតម្លៃទីផ្សារ ។

**៤.៣. ការបញ្ចូលមូលដ្ឋានអាជីវកម្មទៅក្នុងរបបស្វ័យប្រកាស៖**

សហគ្រាសទាំងឡាយដែលបានទទួលធ្វើ ឬផ្គត់ផ្គង់អ្វីមួយ ឬក៏ច្រើនជូនអង្គការសាធារណៈ ហើយដែលមានចំនួនទឹកប្រាក់សរុបទាំងអស់លើសពី ១២៥.០០០.០០០ (មួយរយម្ភៃប្រាំលាន) រៀល សហគ្រាសទាំងនោះ ត្រូវស្ថិតក្នុងក្របខ័ណ្ឌនៃការកំណត់ពន្ធតាមរបបពិតប្រាកដ ឬរបបស្វ័យប្រកាស ដោយមិនគិតពីផលរបរប្រចាំឆ្នាំផងទេ។ តាមការធ្វើសវនកម្មនៅសាខាពន្ធដារខណ្ឌនៃរាជធានីភ្នំពេញ និងសាខាពន្ធដារខេត្តមួយចំនួន អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានមូលដ្ឋានអាជីវកម្មដែលស្ថិតក្នុងរបបម៉ៅការមួយចំនួនបានធ្វើការផ្គត់ផ្គង់ទំនិញ និងសេវាទៅឱ្យអង្គភាពរដ្ឋដោយផលរបរប្រចាំឆ្នាំសរុបមានចំនួនលើសពី ១២៥.០០០.០០០ (មួយរយម្ភៃប្រាំលាន) រៀល ប៉ុន្តែមិនត្រូវបានអង្គភាពពន្ធដារចាត់បញ្ចូលទៅក្នុងរបបស្វ័យប្រកាសឡើយ។

**៤.៤. ភាពសហការរវាងអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា៖** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបង្កើតក្រុមការងារចម្រុះរវាងអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដោយបានតម្រូវឱ្យអង្គភាពទាំងពីរនេះធ្វើកិច្ចសហការគ្នាផ្លាស់ប្តូរព័ត៌មានទិន្នន័យបញ្ជីឈ្មោះសហគ្រាស និងសកម្មភាពអាជីវកម្ម ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងបង្ក្រាបអំពើរត់ពន្ធផ្សេងៗ។ ប៉ុន្តែតាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិ

សង្កេតឃើញថា ទោះបីសហគ្រាសមួយចំនួនដែលគ្មានឈ្មោះក្នុងបញ្ជីចរន្តពន្ធដារ ឬស៊ុំផ្អាកសកម្មភាពអាជីវកម្មក្តី ប៉ុន្តែសហគ្រាសទាំងនោះនៅតែអាចធ្វើសកម្មភាពនាំទំនិញចូលបានជាធម្មតា ដែលទាំងនេះសបញ្ជាក់ឱ្យឃើញថា កិច្ចសហការរវាងអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានៅមិនទាន់មានប្រសិទ្ធភាពខ្ពស់នៅឡើយ ។

**៤.៥. ការគ្រប់គ្រងប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់៖** ការប្រមូលពន្ធនេះអាចប្រព្រឹត្តទៅបានប្រកបដោយប្រសិទ្ធភាពចាំបាច់ត្រូវមានការរៀបចំឱ្យមានបញ្ជីតម្លៃមូលដ្ឋានគិតពន្ធ និងការបង្កើតបញ្ជីដីត្រូវជាប់ពន្ធតាមតំបន់ និងរាជធានី-ខេត្តនីមួយៗឱ្យបានច្បាស់លាស់ និងសមស្រប។ ប៉ុន្តែតាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់តាមរាជធានី-ខេត្តមួយចំនួន ពុំទាន់អនុវត្តឱ្យបានពេញលេញតាមតួនាទីរបស់ខ្លួននោះទេ។

**៤.៦. ការគ្រប់គ្រងអ្នកជាប់ពន្ធតាមរបបមៅការ៖** ច្បាប់ស្តីពីសារពើពន្ធ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសារពើពន្ធបានកំណត់ថា អ្នកជាប់ពន្ធតាមរបបមៅការមានកាតព្វកិច្ចដាក់លិខិតប្រកាសសារពើពន្ធជូនរដ្ឋបាលសារពើពន្ធជារៀងរាល់ឆ្នាំយ៉ាងយឺតបំផុតនៅថ្ងៃទី៣១ ខែតុលា។ ចំនួនទឹកប្រាក់មៅការត្រូវកំណត់ដោយរដ្ឋបាលសារពើពន្ធ បន្ទាប់ពីបានពិនិត្យ និងពិភាក្សាជាមួយអ្នកជាប់ពន្ធ ឬអ្នកតំណាង និងប្រាក់ចំណោញទៅតាមប្រភេទ និងតាមមុខរបរអាជីវកម្ម ដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង

ហិរញ្ញវត្ថុ។ ការកម្រិតពន្ធលើប្រាក់ចំណេញមៅការត្រូវកំណត់ជាស្ថិរវន្តសម្រាប់រយៈពេលមួយកំណត់៣ខែ ៦ខែ ឬមួយឆ្នាំ អ្នកជាប់ពន្ធលើប្រាក់ចំណេញរបបមៅការ ត្រូវបង់ពន្ធនេះជារៀងរាល់ខែតាមពេលវេលាដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ។ ប៉ុន្តែតាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មន្ត្រីពន្ធដារនៃសាខាពន្ធដារខណ្ឌ និងខេត្តនានា បានចុះប្រមូលប្រាក់ពន្ធដល់អាជីវកម្មដ្ឋាន ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួនផ្ទាល់ ពោលគឺម្ចាស់អាជីវកម្មដ្ឋាន ពុំបានទៅបង់ពន្ធនៅរដ្ឋបាលសារពើពន្ធនោះទេ។

**៤.៧. ការប្រមូលពន្ធតាមរបបមៅការៈ** ការប្រមូលពន្ធតាមរបបនេះអាចប្រព្រឹត្តទៅបានពេញលេញលុះត្រាតែអាជីវកម្មដ្ឋានទាំងឡាយត្រូវបានចុះបញ្ជីអនុម័តពន្ធត្រឹមត្រូវ។ រដ្ឋបាលសារពើពន្ធមានតួនាទីជំរឿនអ្នកជាប់ពន្ធ កំណត់ពន្ធ និងដាក់បញ្ចូលអាជីវកម្មក្នុងបញ្ជីអនុម័តពន្ធ។ ប៉ុន្តែតាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អាជីវកម្មដ្ឋានមួយចំនួនមិនទាន់ត្រូវបានបញ្ចូលទៅក្នុងបញ្ជីអនុម័តពន្ធនោះទេ។

**៤.៨. ការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុៈ** ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុបានបញ្ជាក់ថា ការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុមានគោលបំណង ដើម្បីជំរុញឱ្យមានការអភិវឌ្ឍអចលនវត្ថុមួយដែលមានភាពទុកចិត្ត និងទទួលយកបានតាមរយៈការត្រួតពិនិត្យគម្រោងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ គ្រប់គ្រងគម្រោងហិរញ្ញវត្ថុ គណនី

អភិវឌ្ឍអចលនវត្ថុ និងការធ្វើសវនកម្មលើការអនុវត្តកិច្ចសន្យាទិញលក់ និងបង្កើនទំនុកចិត្តរបស់អតិថិជនក្នុងការវិនិយោគលើអចលនវត្ថុ។ ប៉ុន្តែតាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រុមហ៊ុនមួយចំនួនបានធ្វើអាជីវកម្មដោយមានការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មត្រឹមត្រូវពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ទន្ទឹមនឹងនេះដែរក៏មានក្រុមហ៊ុនដែលបាន និងកំពុងធ្វើអាជីវកម្មមួយចំនួនទៀតពុំមានអាជ្ញាប័ណ្ណអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅឡើយ។

**៤.៩. ការជម្រះផ្ទេរចំណូលចូលថវិកា៖** ច្បាប់ និងគោលការណ៍ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ ចំណូលត្រូវកត់ត្រាចូលទាំងស្រុងមិនត្រូវទូទាត់ជាមួយចំណាយឡើយ។ ចំណូលថវិកាទាំងអស់ទោះបីស្ថិតក្នុងប្រភេទចំណូលណាក៏ដោយ ក៏អាណាប័កគ្មានសិទ្ធិដកយកទៅចំណាយ ឬមួយពន្យារការបង់ចូលថវិកាជាតិដើម្បីទុកប្រើប្រាស់ជាផលប្រយោជន៍ណាមួយបានឡើយ។ ប៉ុន្តែតាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពប្រតិបត្តិចំណូលមួយចំនួនរមែងតែងដកចំណូលយកទៅចំណាយ និងមានការពន្យារពេលក្នុងការបង់ចូលថវិកាផងដែរ។ ដោយឡែកនៅក្នុងឆ្នាំ២០១១នេះ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ ចំនួនប្រាក់ចំណូលសរុបប្រមាណជាង ១៨.០០០.០០០.០០០ (ដប់ប្រាំបីពាន់លាន) រៀល មិនទាន់ត្រូវបានផ្ទេរចូលថវិកានៅឡើយ។

**៤.១០. ការតាមដានលើការប្រើប្រាស់ទំនិញនាំចូលក្រោមរបបអនុគ្រោះពន្ធ៖** នាយកដ្ឋានរបបគយនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាមានតួនាទីភារកិច្ចធ្វើការតាមដានសម្ភារ បរិក្ខារ និងទំនិញ

គ្រប់ប្រភេទ ដែលទទួលបានការអនុគ្រោះពន្ធនានាតាមទិសដៅដែលបានកំណត់ និងត្រួតពិនិត្យលើការប្រើប្រាស់ដោយរួមទាំងការចុះទៅបំពេញភារកិច្ចតាមដាន និងឃ្លាំមើលជាអចិន្ត្រៃយ៍ ឬលក្ខណៈម្តងម្កាលតាមបណ្តាអាជីវកម្មដ្ឋាន ឬពាណិជ្ជកម្មនានាស្របតាមនីតិវិធីច្បាប់ជាធរមាន។ ប៉ុន្តែតាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ពុំមានឯកសារ ឬរបាយការណ៍ ឬកំណត់ហេតុដែលអាចបញ្ជាក់ថា នាយកដ្ឋាននេះបានធ្វើការត្រួតពិនិត្យតាមដានលើការប្រើប្រាស់សម្ភារ បរិក្ខារ និងវត្ថុធាតុដើមទាំងឡាយដែលបាននាំចូលដោយពន្ធ និងអាករជាបន្ទុករបស់រដ្ឋនោះឡើយ ដោយពង្រឹងប្រសិទ្ធភាពការអនុវត្តយន្តការសវនកម្មក្រោយពេលបញ្ចេញទំនិញវិញ។

**៤.១១. ការដោះស្រាយទំនិញគ្មានការទាមទារ** ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការគ្រប់គ្រងទំនិញគ្មានការទាមទារបានបញ្ជាក់ថា ក្រោយរយៈពេលហុកសិបថ្ងៃ(៦០ថ្ងៃ) គិតពីថ្ងៃចេញប្រវេសន៍សាធារណៈ ម្ចាស់ទំនិញត្រូវធ្វើការទាមទារទំនិញរបស់ខ្លួន។ ប្រសិនបើហួសរយៈពេលនេះ ទំនិញត្រូវដាក់លក់ដោយការដាក់ឱ្យដេញថ្លៃជាសាធារណៈស្របតាមបញ្ញត្តិនៃប្រកាសនេះ។ ប៉ុន្តែតាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រហូតមកដល់ឆ្នាំ២០១១នេះ កុងតឺន័រទំនិញចំរុះនៅសានាគយ និងរដ្ឋាករផែអន្តរជាតិក្រុងព្រះសីហនុ ដែលសល់តាំងពីឆ្នាំ១៩៩៩បន្តបន្ទាប់មកចំនួន១៣១កុងតឺន័រ នៅពុំទាន់ត្រូវបានធ្វើការដោះស្រាយនៅឡើយ។

៤.១២. ការរក្សាទុកប្រាក់លក់ទំនិញរឹបអូស និងទំនិញបាត់ឃ្លាំង៖ ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការគ្រប់គ្រងលើទំនិញនាំចូលបានបញ្ជាក់ថា ផលពីការលក់ទំនិញដែលនៅសល់ក្រោយពីការចំណាយផ្សេងៗត្រូវដាក់ក្នុងបេឡានៃនិក្ខិត្តភ័ណ្ឌ និងបញ្ញើ ត្រូវទុករយៈពេល២ឆ្នាំ ដើម្បីរង់ចាំម្ចាស់ទំនិញ ឬសិទ្ធិលាភទាំងឡាយ ហើយផុតរយៈពេលវេលានេះត្រូវបានជាគុណប្រយោជន៍ដល់ថវិការដ្ឋ។ ប៉ុន្តែតាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ផលពីការលក់ទំនិញរឹបអូស និងលក់ទំនិញបាត់ឃ្លាំងផ្សេងៗផុតរយៈពេល២ឆ្នាំមួយចំនួនត្រូវបានអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាដកយកទៅប្រើប្រាស់ក្នុងការផ្តល់រង្វាន់លើកទឹកចិត្តនិងចំណាយផ្សេងៗ។ គិតមកដល់ចុងឆ្នាំ២០១១នេះ ទឹកប្រាក់ដែលនៅសល់នេះ ហើយដែលពុំពាក់ព័ន្ធនឹងម្ចាស់ទំនិញ ឬសិទ្ធិលាភទាំងឡាយនោះចំនួនជាង ៩០០.០០០.០០០ (ប្រាំបួនរយលាន) រៀល និងជាង៥០០.០០០ (ហាសិបម៉ឺន) ដុល្លារអាមេរិក អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៅតែមិនទាន់បានបង់ចូលថវិការដ្ឋនៅឡើយ។

៤.១៣. ការរក្សាទុកសាច់ប្រាក់ក្នុងបេឡាលើសកម្រិតកំណត់៖ សារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែលម្អនីតិវិធីអនុវត្តថវិកាបានកំណត់ចំនួនទឹកប្រាក់ចំណូលរបស់រដ្ឋ ភ្នាក់ងារ ឬអង្គភាពប្រតិបត្តិនីមួយៗអាចរក្សាទុកនៅក្នុងបេឡារបស់ខ្លួនត្រឹមចំនួនពី២លានរៀល ទៅ៥លានរៀលប៉ុណ្ណោះ។ ប៉ុន្តែតាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពប្រតិបត្តិ

ចំណូលមួយចំនួននៅតែរក្សាទុកសាច់ប្រាក់ចំណូលក្នុងបេឡារបស់ខ្លួនលើសកម្រិតកំណត់ ព្រមទាំងរក្សាទុកយូរថ្ងៃទើបបង់ចូលថវិកា។

**៤.១៤.ការកត់ត្រាចំណូលថវិការរដ្ឋ៖** បទបញ្ញាទូទៅនៃគណនេយ្យសាធារណៈកំណត់ថា ការកត់ត្រាចំណូលថវិកាត្រូវផ្អែកលើមូលដ្ឋានសលាកប័ត្រ ឬដីកាចំណូលរបស់អាណាប័កក្រសួង-ស្ថាប័ន រាជធានី-ខេត្ត ដែលបានរៀបចំបញ្ជូនទៅឱ្យអគ្គនាយកដ្ឋានរតនាគារជាតិដើម្បីធ្វើការផ្ទៀងផ្ទាត់។ ប៉ុន្តែតាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ចំណូលមួយចំនួនមិនត្រូវបានកត់ត្រាដោយផ្អែកលើមូលដ្ឋានសលាកប័ត្រ ឬដីកាចំណូលរបស់អាណាប័កនៅឡើយដោយសារក្រសួង-ស្ថាប័នមួយចំនួនតូច មិនព្រមធ្វើសលាកប័ត្រចំណូលមកឲ្យអគ្គនាយកដ្ឋានរតនាគារជាតិ។

អាជ្ញាធរសវនកម្មជាតិក៏បានសង្កេតឃើញថា ករណីទាំងនេះពាក់ព័ន្ធនឹងប្រភេទចំណូលមួយចំនួនដែលបានកើតមាននៅពេលកៀកចុងឆ្នាំ ហើយជាប្រភេទចំណូលដែលគ្រាន់តែធ្វើនិយ័តកម្មតួលេខដូចជា៖ ចំណូលពីលំអៀងលើសនៃអត្រាប្តូរប្រាក់ចំណូលពីកម្រៃរតនាគារ ចំណូលពីវិសមភាពបេឡា និងខ្ទង់ចំណូលមួយចំនួនទៀតនៅកៀកចុងឆ្នាំដូចជា ចំណូលពីសំណោះចំណាយ ចំណូលពីការប្រាក់ និងប្រាក់ដើម ចំណូលពីជំនួយសហគមន៍អឺរ៉ុបផ្តល់ឱ្យក្រសួងអប់រំ យុវជន និងកីឡា និងចំណូលពីឈ្នួលទីតាំងដែលធនាគារជាតិនៃកម្ពុជា បានបញ្ជូនប្រកាសឥណទានមកឱ្យអគ្គនាយកដ្ឋានរតនាគារជាតិហើយ ប៉ុន្តែក្រសួង-ស្ថាប័នមួយចំនួនតូចមិនព្រមធ្វើសលាកប័ត្រចំណូលមកឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ ហើយ

ដែលរតនាគារជាតិត្រូវបង្ខំចិត្តធ្វើការកត់ត្រាឱ្យបានទាន់ពេលវេលា នៅពេលបិទបញ្ជីចុងឆ្នាំ។ បញ្ហានេះ ប្រសិនបើអគ្គនាយកដ្ឋានរតនាគារ-ជាតិមិនបានកត់ត្រាជាចំណូលទេនោះនឹងនាំឱ្យមានការបាត់បង់ចំណូលរបស់ជាតិ ព្រោះថាសាច់ប្រាក់បានបង់ចូលបេឡារបស់រដ្ឋរួចហើយ។

**៤.១៥. ការទូទាត់ និងការកត់ត្រាចំណាយៈ** ជាគោលការណ៍ ការបញ្ជូនអាណត្តិបើកប្រាក់ទៅអគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវបានកំណត់ឱសានវាទត្រឹមថ្ងៃទី៣១ ខែធ្នូនៃឆ្នាំសារពើពន្ធ។ ប៉ុន្តែតាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការបញ្ជូនអាណត្តិបើកប្រាក់ទៅអគ្គនាយកដ្ឋានរតនាគារជាតិ នៅតែមានភាពយឺតយ៉ាវ និងមិនទាន់សមស្រប ដូចជាអាណត្តិបើកប្រាក់មួយចំនួនដែលបានបោះផ្សាយរួចហើយពុំទាន់បានធ្វើការទូទាត់ និងកត់ត្រាចំណាយទាន់ពេលវេលា អាណត្តិបើកប្រាក់មួយចំនួនតែងតែបានបញ្ជូនទៅរតនាគារជាតិធ្វើការទូទាត់នៅក្រោយថ្ងៃឱសានវាទបិទបញ្ជី ដែលបង្កឱ្យមានការកកស្ទះអាណត្តិបើកប្រាក់ និងលំបាកក្នុងការបូកសរុបបិទបញ្ជីប្រចាំឆ្នាំ។

អាជ្ញាធរសេនវកម្មជាតិសង្កេតឃើញថា ជាទូទៅអាណត្តិដែលបានបញ្ជូនចេញពីអគ្គនាយកដ្ឋានថវិកា ក៏ដូចជាពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានធ្វើទៅតាមកាលបរិច្ឆេទកំណត់ (ត្រឹមថ្ងៃទី៣១ ខែធ្នូ នៃការិយបរិច្ឆេទ)។ ប៉ុន្តែនៅមានអាណត្តិមួយចំនួនតូចដែលត្រូវការទូទាត់ចំណាយជាចាំបាច់ភ្ជាប់ជាមួយនូវសក្ខីប័ត្រគ្រប់គ្រាន់ ដោយប្រើប្រាស់ឥណទានដែលនៅសល់ក្នុងឆ្នាំ។

**៤.១៦. ការទូទាត់ប្រាក់បុរេប្រទានៈ** ៖ ប្រាក់បុរេប្រទានគឺជាប្រាក់បើកផ្តល់ឱ្យចំណាយមុនក្នុងករណីមានការចាំបាច់ ឬបន្ទាន់។ ជារៀងរាល់ឆ្នាំ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែងតែបានចេញប្រកាស និងសារាចរណែនាំដល់គ្រប់ក្រសួង-ស្ថាប័នឱ្យរួសរាន់ប្រមូលឯកសារ ដើម្បីស្នើសុំទូទាត់ប្រាក់បុរេប្រទាន ដែលបានចំណាយរួចហើយឱ្យបានមុនដំណាច់ឆ្នាំ ដោយគិតរួមទាំងចំណាយប្រាក់បុរេប្រទានជាថវិកាប័ណ្ណអន្តរជាតិដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានផ្តល់ឱ្យតាមរយៈមូលប្បទានប័ត្រផងដែរ។ ក្នុងការអនុវត្តកន្លងមក អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួង-ស្ថាប័នមួយចំនួនតូច ក្រោយពីការចំណាយរួចហើយ ពុំសូវបានរួតរះប្រមូលឯកសារ ដើម្បីស្នើសុំទូទាត់ឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលានោះទេ។ ជាក់ស្តែង គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ ប្រាក់បុរេប្រទានដែលបានប្រតិបត្តិចំណាយរួចហើយ តែពុំទាន់មានឯកសារទូទាត់ជម្រះមានចំនួន ២០៧.២០៥.៣៥៥.៦៨១ រៀល។ ដោយមូលហេតុនេះ វាបង្កឱ្យទឹកប្រាក់បុរេប្រទានត្រូវបានកកស្ទះនឹងកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ ហើយក៏មានករណីខ្លះទៀត ដូចជាបុរេប្រទានជាមូលប្បទានបត្រដែលកន្លងមកនាយកដ្ឋានកិច្ចការអាស៊ាននៃក្រសួង-ស្ថាប័ននីមួយៗស្នើសុំទូទាត់ត្រង់ពីអាណាប័កដើមខ្សែមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានអាស៊ាន) តែម្តង។ ដូច្នេះ នាយកដ្ឋានដែលបានថវិកាយកទៅចំណាយហើយ មិនសូវគិតគូរពីការប្រមូលសក្ខីបត្រឱ្យនាយកដ្ឋានហិរញ្ញវត្ថុ ដើម្បីជាមូលដ្ឋានស្នើសុំទូទាត់មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឡើយ។

**៤.១៧.ការដកចំណូលយកទៅចំណាយ៖** ច្បាប់ និងលិខិតបទដ្ឋាននានាស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុបានកំណត់ថា ចំណូលដែលប្រមូលបានត្រូវបង់ចូលថវិកា ដោយមិនត្រូវបានអនុញ្ញាតឱ្យធ្វើការទូទាត់ជាមួយចំណាយណាមួយឡើយ។ ប៉ុន្តែអាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពប្រតិបត្តិចំណូលមួយចំនួន តែងតែដកចំណូលយកទៅប្រើប្រាស់ក្នុងរូបភាពដករង្វាន់ និងចំណាយផ្សេងៗតាមបទប្បញ្ញត្តិពាក់ព័ន្ធនឹងការបែងចែកប្រាក់រង្វាន់ជាធរមាននៅមុនការបង់ចូលថវិការដ្ឋ។

**៤.១៨.ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ** ៖ អនុក្រឹត្យរបស់រាជរដ្ឋាភិបាល និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធលទ្ធកម្មសាធារណៈបានបញ្ជាក់ថា ស្ថាប័នអនុវត្តលទ្ធកម្មត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំខែទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានទៀងទាត់។ ប៉ុន្តែតាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួង-ស្ថាប័ន សាលារាជធានី-ខេត្ត និងសហគ្រាសសាធារណៈមួយចំនួន ពុំបានធ្វើរបាយការណ៍ស្តីពីការអនុវត្តន៍កិច្ចលទ្ធកម្មប្រចាំខែទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានទៀងទាត់ និងទាន់ពេលវេលានោះទេ។ ជាក់ស្តែង សម្រាប់ការិយបរិច្ឆេទ២០១១នេះ មានក្រសួង-ស្ថាប័នចំនួន១៣ សាលាខេត្តចំនួន ០១ និងសហគ្រាសសាធារណៈចំនួន១១ មិនបានធ្វើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំខែទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**៤.១៩. ការធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ៖** សារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលធ្វើបញ្ជី

សារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋបានតម្រូវឱ្យគ្រប់ក្រសួង-ស្ថាប័ន និងសាលារាជធានី-ខេត្តធ្វើបញ្ជីសារពើភ័ណ្ឌលម្អិតសម្រាប់ឆ្នាំ ២០០៤ ឱ្យបានជាដាច់ខាត ដើម្បីទុកជាឆ្នាំគោលសម្រាប់ការប្រៀបធៀបបញ្ជីសារពើភ័ណ្ឌឆ្នាំ២០០៥ និងនៅបណ្តាឆ្នាំចន្លោះ០៥ឆ្នាំស្តីពីការកើនឡើង និងថយចុះនៃទ្រព្យសម្បត្តិរដ្ឋ។ ប៉ុន្តែតាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋមួយចំនួនពុំបានអនុវត្តឱ្យបានពេញលេញតាមការតម្រូវខាងលើនេះទេ ដោយអង្គភាពមួយចំនួននៅតែមានការយឺតយ៉ាវក្នុងការធ្វើបញ្ជីសារពើភ័ណ្ឌឆ្នាំគោល ហើយខ្លះទៀតយឺតយ៉ាវក្នុងការរៀបចំតារាងប្រៀបធៀបការកើនឡើង និងថយចុះនៃទ្រព្យសម្បត្តិរដ្ឋ។

**៤.២០. ការធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ៖** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែងតែបានចេញលិខិត និងសារាចរណែនាំផ្សេងៗណែនាំឱ្យក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងសាលារាជធានី-ខេត្ត ដែលជាអង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ ត្រូវធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិលើអចលនទ្រព្យ ដែលបាននិងកំពុងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួនឱ្យបានគ្រប់ចំនួននិងឆាប់រហ័ស ជាប្រយោជន៍ដើម្បីធានាបាននូវភាពគង់វង្ស និងភាពស្របច្បាប់នៃទ្រព្យសម្បត្តិទាំងឡាយនោះ។ ប៉ុន្តែតាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រហូតមកដល់ឆ្នាំ២០១១នេះ ទ្រព្យសម្បត្តិរដ្ឋមួយចំនួននៅតែពុំទាន់បានធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិរួចរាល់នៅឡើយ។

## ៥. សេចក្តីសន្និដ្ឋាន

លទ្ធផលនៃការអនុវត្តច្បាប់ហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១១ បានបង្ហាញឱ្យឃើញថា រាជរដ្ឋាភិបាលកម្ពុជាធ្វើឱ្យសម្រេចបាននូវកំណើនសេដ្ឋកិច្ច ៧,១% លើសពីការព្យាករណ៍ដែលបានរំពឹងទុកក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១១ មានតែ ៦% ប៉ុណ្ណោះ ព្រមទាំងសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រក្នុងអាត្រាជាង ១% ក្នុងមួយឆ្នាំ ដែលធ្វើឱ្យគោលដៅកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលសម្រេចបានមុនគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។

តាមរយៈការផ្តល់អនុសាសន៍កែលម្អនូវចំណុចខ្វះខាតនានា និងការចេញផ្សាយរបាយការណ៍សវនកម្មជាសាធារណៈជាបន្តបន្ទាប់មកនេះ អាជ្ញាធរសវនកម្មជាតិកត់សម្គាល់ឃើញថា អង្គភាពរងសវនកម្មនានា ពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានយកចិត្តទុកដាក់ខិតខំអនុវត្តកែលម្អគួរឱ្យស្ងើចសរសើរ ទោះបីចំណុចមួយចំនួននៅមិនទាន់ត្រូវបានអនុវត្តឱ្យបានប្រសើរនៅឡើយក៏ដោយ។ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា អង្គភាពរងសវនកម្មទាំងឡាយនឹងបន្តខិតខំអនុវត្តកែលម្អនូវរាល់កង្វះខាតទាំងនោះបានល្អប្រសើរ និងទាន់ពេលវេលា ហើយជៀសវាងបាននូវការបន្តកើតមានកង្វះខាតដដែលៗជាបន្តទៅទៀត ដើម្បីចូលរួមចំណែកយ៉ាងសកម្មក្នុងការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យបានកាន់តែរឹងមាំ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

ក្នុងបរិបទនេះដែរ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានធ្វើរបាយការណ៍គោរពជូនសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា លើលទ្ធផលការងារអធិការកិច្ចហិរញ្ញវត្ថុ ដែលបានរកឃើញនូវកំហុសឆ្គងរបស់ក្រសួង-ស្ថាប័ន សហគ្រាសសាធារណៈ

និងមន្ទីរជំនាញ និងបានធ្វើលិខិតចាត់វិធានការវិន័យរដ្ឋបាល ដើម្បីកែលម្អកំហុសឆ្គងលើការអនុវត្តនីតិវិធីហិរញ្ញវត្ថុ ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានរកឃើញក្នុងការគ្រប់គ្រង ការប្រើប្រាស់ចំណូល ចំណាយថវិការដ្ឋ ចំណូលមិនមែនសារពើពន្ធ កាតព្វកិច្ចបង់ចំណូលចូលថវិការដ្ឋ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ និងមន្ទីរជំនាញ ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពតាមនីតិវិធីហិរញ្ញវត្ថុ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ហើយបានចម្លងជូនក្រសួង ស្ថាប័នពាក់ព័ន្ធដូចជា៖ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច អង្គភាពប្រឆាំងអំពើពុករលួយ និងអាជ្ញាធរសវនកម្មជាតិ ដើម្បីចាត់ការបន្ត។

ទន្ទឹមនឹងនេះដែរ អាជ្ញាធរសវនកម្មជាតិមានជំនឿយ៉ាងមុតមាំថា ក្រសួង-ស្ថាប័ន អង្គភាពពាក់ព័ន្ធនានា និងសាធារណជនទាំងឡាយនឹងបន្តចូលរួមផ្តល់មតិស្ថាបនាលើរបាយការណ៍នេះ ព្រមទាំងផ្តល់ការលើកទឹកចិត្តចំពោះលទ្ធផលសម្រេចបាន ដែលជាកត្តាជំរុញឱ្យអាជ្ញាធរសវនកម្មជាតិ បន្តខិតខំបង្កើនសមត្ថភាពការងាររបស់ខ្លួនប្រកបដោយសីលធម៌វិជ្ជាជីវៈ សំដៅលើកកម្ពស់គុណភាពសវនកម្មឱ្យស្របតាមស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងស្តង់ដារតំបន់ និងអន្តរជាតិ ដើម្បីចូលរួមចំណែកក្នុងការកសាង និងអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព។